**អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប)**

*“ការអភិវឌ្ឍមនុស្សប្រកបដោយសេចក្តីថ្លៃថ្នូរ”*











# របាយការណ៍ប្រចាំឆ្នាំ ២០១៩

**ចេញផ្សាយនៅថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២០**


ការិយាល័យៈ សាលាគរុកោសល្យ និងវិក្រិតការខេត្ត ផ្លូវជាតិលេខ ៧ចាស់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម
ប្រអប់សំបុត្រៈ P.O Box ១៦២១ ភ្នំពេញ កម្ពុជា

042-941-481 / 042-941-918 kape@kapekh.org www.kapekh.org

Find us on Facebook www.facebook.com/kapeaction Follow us on twitter www.facebook.com/kapeaction

YouTube www.youtube.com/TheKapeCambodia

LinkedIn www.linkedin.com/company/kampuche an-action-for-primary-education


***សម្គាល់:*** *សូមមើលអំពីផលជះរបស់គម្រោងនីមួយៗ នៅលើគេហទំព័រអង្គការ ខេប។ លោកអ្នកអាចអាន ករណីសិក្សាបន្ថែមតាមរយៈតំណភ្ជាប់:*

*kapekh.org/en/what-we-do/4/?pro_id=20*

(អង្គការ ខេប បានចុះបញ្ជីនៅក្រសួងមហាផ្ទៃក្នុងឆ្នាំ១៩៩៩)

# សារប្រធានក្រុមប្រឹក្សាភិបាល



*ក្នុងនាមក្រុមប្រឹក្សាភិបាលអង្គការ ខេប ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង និងឯកភាពទៅលើរបាយការណ៍ប្រចាំឆ្នាំ២០១៩ ដែលចាប់ផ្តើមពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៩នេះ។ របាយការណ៍នេះបានបង្ហាញទាំងដំណើរការកម្មវិធីជោគជ័យនៅក្នុងបរិយាកាសប្រតិបត្តិការ សមិទ្ធផលថ្មីៗ និងការពង្រីកប្រភពផ្តល់មូលនិធិ។ ម្យ៉ាងវិញទៀត បរិយាកាសប្រតិបត្តិការកម្មវិធីមានការលំបាកនៅពេលបច្ចុប្បន្ននេះ។ ជាពិសេស របាយការណ៍នេះមានលក្ខណៈប្លែកដោយសារចំខួបលើកទី២០របស់អង្គការ ខេប និងជាពេលដែលអង្គការ ខេប ចាប់ផ្តើមអភិវឌ្ឍន៍នៅក្នុងទសវត្សរ៍ទី៣។ ក្រុមប្រឹក្សាភិបាលសូមចូលរួមអបអរសាទរដល់បុគ្គលិកអង្គការ ខេប ទាំងអស់ដែលបានខិតខំពុះពារជួយកុមារកម្ពុជាដែលមានវិបត្តិឱ្យទទួលបានសេវាអប់រំមានគុណភាពខ្ពស់ រក្សាបាននូវស្តង់ដាអភិបាលកិច្ចល្អ មានតម្លាភាព និងមានប្រសិទ្ធភាពក្នុងការប្រើប្រាស់មូលនិធិ៕*

**ប្រធានក្រុមប្រឹក្សាភិបាល**



**ហ៊ាង កុយ**

ខេបគឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដែលធ្វើការចម្បងនៅក្នុងវិស័យអប់រំក្នុងប្រព័ន្ធនៅក្នុងប្រទេសកម្ពុជា។ ខេបបានប្រតិបត្តិការគម្រោងនៅគ្រប់កម្រិតជាមួយអ្នកទទួលផលនៅក្នុងសាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ និងកម្មវិធីអាហារូបករណ៍សម្រាប់សិស្សនៅសាកលវិទ្យាល័យ។ ចំនួនកុមារទទួលផលផ្ទាល់មានជាង ៧១.000នាក់ និងគ្រូបង្រៀនជាច្រើនរយនាក់ ដែលបង្រៀននៅជាង ១៦៥សាលាក្នុង១៤ខេត្ត-រាជធានី។

**ចក្ខុវិស័យ:** ចក្ខុវិស័យរបស់ ខេប គឺផ្តល់លទ្ធភាពដល់កុមារ និងយុវជននូវជម្រើសដ៏ល្អបំផុតនៅក្នុងជីវិតផ្អែកលើសក្តានុពលរបស់ពួកគេតាមរយៈការទទួលបានការអប់រំល្អ។

**បេសកកម្ម:** បេសកកម្មរបស់ខេប គឺធ្វើការជាមួយរដ្ឋាភិបាល សហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីផ្តល់អំណាចដល់កុមារ និងយុវជនរងគ្រោះក្នុងការសម្រេចបាននូវសិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាពតាមរយៈវិធីច្នៃប្រឌិតថ្មី។

## គុណតម្លៃ

- ការផ្តល់សិទ្ធិអំណាច
- ការសាមគ្គី
- សេចក្តីមេត្តា
- ការគោរព
- កិច្ចសហប្រតិបត្តិការ
- ការកែប្រែថ្មី/ច្នៃប្រឌិតថ្មី
- តម្លាភាព
- ជឿជាក់

# មាតិកា

សារប្រធានក្រុមប្រឹក្សាភិបាល........2
សារនាយកប្រតិបត្តិ........3
សេចក្តីសង្ខេប........4
ការឆ្លុះបញ្ចាំងទៅថ្ងៃអនាគត........5
ព័ត៌មានសំខាន់ៗ និងព្រឹត្តិការណ៍អន្តរជាតិ........6
ធីធីអ្វ អ៊ីមផត អិចផត ឯ.ក........11

## កម្មវិធី

គម្រោង សាលារៀនជំនាន់ថ្មី (NGS)........12
គម្រោង សាលារៀនជំនាន់ថ្មី(NGS)-ស្វាយរៀង........14
គម្រោង សៀវភៅសម្រាប់កម្ពុជា (BfC)........16
គម្រោង ស្បៀងអាហារសម្រាប់ការអប់រំ (FFE)........17
កម្មវិធី អប់រំបញ្ចូលគ្នា (IEP)........18
គម្រោង កុមារកម្ពុជារីករាយ (HCC)........23
គម្រោង ងាយស្រួលរៀន (E2L)........24
គម្រោង បរិស្ថានសិក្សាប្រកបដោយគុណភាព (QLE Expansion)........26
គម្រោង វិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (TRAC III)........27
គម្រោង បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ (REACHIII)..28
គម្រោង អប់រំបំណិនជីវិតសម្រាប់កុមារី (LSLAG)........30
គម្រោង លើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន (TIGER).....31

ការបង្ហាញហិរញ្ញវត្ថុក្នុងឆ្នាំ២០១៩........32
ក្រុមអ្នកគ្រប់គ្រងនៅក្នុងឆ្នាំ២០១៩........33
រចនាសម្ព័ន្ធអង្គការ ខេប នៅក្នុងឆ្នាំ២០១៩........34

# សារនាយកប្រតិបត្តិ



ដោយក្តីសោមនស្សរីករាយ អង្គការ **ខេប** សូមចែករំលែករបាយការណ៍ប្រតិបត្តិការប្រចាំឆ្នាំនេះជាមួយដៃគូរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ហើយវាក៏ជាខួបគម្រប់ទី២០ឆ្នាំផងដែរ និងជាការចាប់ផ្តើមនៃទសវត្សរ៍ថ្មីក្នុងបេសកកម្មផ្តល់សេវាកម្មជួយកុមារ និងយុវជនកម្ពុជា។ ក្រោយបានបង្កើតឡើងនៅឆ្នាំ១៩៩៩អង្គការ ខេប មានបេសកកម្ម ចក្ខុវិស័យផ្តោតសំខាន់លើការអប់រំនៅកម្រិតមូលដ្ឋាន។ បច្ចុប្បន្ននេះ **ខេប** បានរីវឌ្ឍខ្លួនទៅជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកឈានមុខធំជាងគេធ្វើការងារ និងគាំទ្រវិស័យអប់រំក្នុងប្រព័ន្ធនៃប្រទេសកម្ពុជា។ តបតាមការរីឌ្ឍ និងការឆ្លុះបញ្ចាំងពីវិសាលភាពដ៏ទូលំទូលាយ អង្គការសម្រេចបានជោគជ័យដ៏សំខាន់មួយទៀតក្នុងឆ្នាំនេះផងដែរ គឺការសុំផ្លាស់ប្តូរឈ្មោះពី **អង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា** ទៅជា **អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (Kampuchea Action to Promote Education (KAPE))**។ បច្ចុប្បន្ន ក្រសួងមហាផ្ទៃបានអនុម័តយល់ព្រមនឹងចេញលិខិតប្រកាសទទួលស្គាល់ជាផ្លូវការកាលពីខែមីនា ឆ្នាំ២០១៩ ហើយអង្គការនៅតែរក្សាបាននូវអក្សរកាត់ដូចគ្នាគឺ **“KAPE”** ដដែលដើម្បីអភិរក្សបាននូវកិត្តិនាមដើមរបស់ខ្លួន។

អង្គការ **ខេប** បានចាប់ផ្តើមបើកទំព័រថ្មីក្នុងទសវត្សទី៣ ចាំបាច់ត្រូវបន្តពង្រឹងតួនាទីការប្រតិបត្តិគម្រោងចំនួន ២០ ដែលមានស្រាប់នឹងកំពុងដំណើរការ ព្រមទាំងកម្រិតថវិកាចំណូលខ្ពស់ជាប្រវត្តិសាស្រ្ត។ នេះគឺជាចំនួនគម្រោងដ៏ច្រើនបំផុតដែលអង្គការ ខេប បានអនុវត្តក្នុងពេលតែមួយ។ គម្រោងថ្មីៗមួយចំនួនបន្តរយៈពេលខ្លី តែផ្តោតលើសកម្មភាពដែលបន្សីគ្នាទៅនឹងគម្រោងផ្សេងៗទៀត។ គម្រោងរយៈពេលខ្លីទាំងនេះ រួមមាន៖ **កម្មវិធីផ្តល់ប្រឹក្សាអាជីពតាមអេឡិចត្រូនិច** (គម្រោងត្រៃវិស័យ) និង**ការអភិវឌ្ឍកម្មវិធីសុសវែរអំណានភាសាខ្មែរ** (កម្មវិធីអំណានភាសាខ្មែរ)។ ចំពោះគម្រោងអតីតគឺមានការទាក់ទងខ្លាំងលើកម្មវិធីយុវជន ខណៈពេលបន្ទាប់កម្មវិធីនេះនឹងផ្តល់តម្លៃខ្ពស់ទៅលើកម្មវិធីអំណានជាច្រើន។

កម្មវិធីថ្មីៗមួយចំនួនដែលបានបន្តភ្ជាប់នៅក្នុងឆ្នាំ២០១៩នេះ គឺកំពុងដំណើរការក្នុងនោះរួមបញ្ចូលទាំងការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីនៅវិទ្យាស្ថានជាតិអប់រំ។ មជ្ឈមណ្ឌលថ្មីនេះនឹងផ្តល់សញ្ញាបត្រអនុបណ្ឌិតផ្នែកប្រឹក្សាគរុកោសល្យដល់បេក្ខជនបានជ្រើសរើស ដែលនឹងជួយឱ្យក្រសួងអប់រំ យុវជន និងកីឡាបង្កើតប្រព័ន្ធប្រឹក្សាគរុកោសល្យនៅគ្រប់សាលារៀនជំនាន់ថ្មី និងសាលាដទៃៗទៀត។ ក្រសួងអប់រំ យុវជន និងកីឡាបានស្នើសុំឱ្យអង្គការ ខេប ជួយគ្រប់គ្រងមជ្ឈមណ្ឌលនេះដែលជាកិត្តិយសដ៏ខ្ពង់ខ្ពស់ និងប្រកបដោយទំនុកចិត្តសម្រាប់អង្គការ ខេប ដែលបានកសាងស្នាដៃជាមួយរាជរដ្ឋាភិបាលលើកម្មវិធីសាលារៀនជំនាន់ថ្មី។ ការបង្កើតមជ្ឈមណ្ឌលនេះមានន័យថា បច្ចុប្បន្ន អង្គការ ខេប មានកម្មវិធីគាំពារកុមារ និងការអភិវឌ្ឍរហូតដល់ការអប់រំថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ (ថ្នាក់អនុបណ្ឌិត)។

កម្មវិធីថ្មីស្រឡាងមួយទៀតនឹងត្រូវចាប់ផ្តើមនាចុងឆ្នាំ២០១៩ នេះគឺ៖ **គម្រោងលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា** (**Strengthening Education & Employability in Kampuchea/SEEK**)។ គម្រោងការថ្មីនេះ បានទទួលហិរញ្ញប្បទានពីសហគមន៍អឺរ៉ុប ហើយវាក៏ជាលើកទីមួយផងដែរដែល **ខេប** ទទួលបានហិរញ្ញប្បទានដោយផ្ទាល់ពីម្ចាស់ជំនួយទ្វេភាគី ឬពហុភាគី។ **ខេប** តែងតែមានក្តីរំពឹងថា ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (**USAID**) នឹងក្លាយជាម្ចាស់ជំនួយទ្វេភាគី ដំបូងគេក្នុងការផ្តល់ហិរញ្ញប្បទានដោយផ្ទាល់របស់ខេប ក៏ប៉ុន្តែខេបបានដាក់អាទិភាពខ្ពស់អភិវឌ្ឍន៍រួមជាមួយសហគមន៍អឺរ៉ុប (ឧទាហរណ៍៖ យុវជន ភាពមានការងារធ្វើ និងការពង្រឹងសង្គមស៊ីវិល) បានផ្លាស់ប្តូរព្រឹត្តិការណ៍ទាំងនេះ។ ខណៈដែលអង្គការ ខេប បន្តផ្តោតការយកចិត្តទុកដាក់ជាយុទ្ធសាស្ត្រទៅលើការផ្លាស់ប្តូរជាប្រវត្តិសាស្ត្ររបស់ខ្លួនក្នុងការទទួលហិរញ្ញប្បទានពីទ្វេភាគី សម្ព័ន្ធភាពជាមួយសហគមន៍អឺរ៉ុបនឹងជួយឱ្យ ខេប លើកកម្ពស់បណ្តាញ និងសារតាខ្លួនបាន។ ម្យ៉ាងវិញទៀត ហិរញ្ញប្បទានទទួលបានភាគច្រើនពីមូលនិធិឯកជន និងរដ្ឋាភិបាលកម្ពុជា។

ក្រៅពីសហភាពអឺរ៉ុប អង្គការ ខេប ក៏បានស្វាគមន៍ម្ចាស់ជំនួយថ្មីៗជាច្រើនទៀតក្នុងឆ្នាំនេះ រួមមាន៖ អង្គការ **Lotus Outreach/** ក្រុមហ៊ុន **GAP** ហើយយើងនឹងនៅតែបន្តទំនាក់ទំនងល្អរឹងមាំជាមួយបណ្តាដៃគូមូលនិធិឯកជន ដូចជា៖ អង្គការមូលនិធិអាស៊ី(**TAF)** មូលនិធិគ្រួសារត្រកូលហ្វ្រេងស៍(**FFF)** មូលនិធិគីនចាន់ មូលនិធិអូកទ្រី អង្គការឆាលហ្វានកម្ពុជា(**CF)** អង្គការ **WeWorld-GVC,** អង្គការ **VVOB** និងអង្គការសង្គ្រោះកុមារអន្តរជាតិ(**SCI)**។

ជាថ្មីម្តងទៀត អង្គការ **ខេប** សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះដៃគូ និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានគាំទ្រច្រើនឆ្នាំកន្លងមកនេះ ហើយយើងទន្ទឹងរង់ចាំបន្តធ្វើការរួមគ្នាដើម្បីកែលម្អប្រព័ន្ធអប់រំសម្រាប់កុមារ និងយុវជនកម្ពុជានៅក្នុងទសវត្សរ៍ថ្មីនេះ។

ថ្ងៃសុក្រ ៧កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

កំពង់ចាម ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០

**នាយកប្រតិបត្តិ**

KAMPUCHEA ACTION TO PROMOTE EDUCATION

**សៅ វណ្ណា**

# សេចក្តីសង្ខេប




នៅដើមឆ្នាំ២០១៩ អង្គការ ខេប បានបញ្ចប់ការចុះឈ្មោះឡើងវិញនៅក្រសួងមហាផ្ទៃ ដែលជាការខិតខំប្រឹងប្រែងដើម្បីអនុលោមតាមច្បាប់អង្គការក្រៅរដ្ឋាភិបាលថ្មី។ ក្នុងអំឡុងដំណើរការចុះឈ្មោះ ខេបបានសម្រេចប្តូរឈ្មោះទៅជា "**អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា**" កាន់តែលេចច្បាស់ថាអង្គការ ខេប មិនបានផ្តោតតែលើការអប់រំបឋមសិក្សាប៉ុណ្ណោះទេ ប៉ុន្តែក៏មានកម្មវិធីគាំពារកុមារ និងការអភិវឌ្ឍ មធ្យមសិក្សា និងកម្មវិធីអប់រំកម្រិតឧត្តមសិក្សាផងដែរ។ ម៉្យាងវិញទៀត ការផ្លាស់ប្តូរឈ្មោះនេះមិនប៉ះពាល់ដល់អក្សរកាត់ទេ គឺនៅរក្សា "**ខេប**" ដដែល។

ក្នុងឆ្នាំ២០១៩ អង្គការ ខេប បានទទួលជោគជ័យថ្មីមួយទាក់ទងនឹងទំហំគម្រោងដែលគាំទ្រជាង ២០ ដែលភាគច្រើនជាគម្រោងអង្គការ ខេប ធ្លាប់អនុវត្តម្តងរួចហើយ (សូមមើលតារាង)។ នៅឆ្នាំ២០១៨ អង្គការ ខេប មានគម្រោងគាំទ្រចំនួន ១៨។ គម្រោងថ្មីចំនួន ៤ ត្រូវបានដំណើរការឡើងវិញក្នុងឆ្នាំសារពើពន្ធនេះ (**គម្រោងអប់រំកុមារី គម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី និងគម្រោងលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា**) ខណៈគម្រោងបួនទៀតបានបញ្ចប់ (**គម្រោងងាយស្រួលរៀន/ស្វាយរៀង គម្រោងស្បៀងអាហារសម្រាប់ការអប់រំ គម្រោងអំណានភាសាខ្មែរ និងគម្រោងត្រីវិស័យ**)។ គម្រោងអង្គការ ខេប នៅតែបន្តមានភាពចម្រុះស្របតាមផែនការយុទ្ធសាស្ត្រខ្លួន និងរួមទាំងកម្មវិធីអំណានថ្នាក់ដំបូង កម្មវិធីយុវជន បច្ចេកវិទ្យាព័ត៌មានអប់រំ សាលាធម្មនុញ្ញ និងភាពជាដៃគូឯកជន-សាធារណៈ។ ក្នុងរបកគំហើញដ៏ធំនាបច្ចុប្បន្ននេះ អង្គការ ខេប ទទួលបានការងារពីក្រសួងអប់រំ ដើម្បីគ្រប់គ្រងកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ (ប្រឹក្សាគរុកោសល្យ) នៅមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី ដែលបានបង្កើតបន្ថែមការអប់រំថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ស្របនឹងវិស័យដែលគាំទ្រដោយអង្គការ ខេប។ ក្នុងបច្ចុប្បន្ននេះ អង្គការ ខេប បានអនុវត្តគម្រោងនៅទូទាំង ១៤ខេត្តក្រុង ដែលមានកុមារ និងយុវជនជាអ្នកទទួលផលជាង ៧០.០០០នាក់។

អំឡុងឆ្នាំនេះ អង្គការ ខេប បានបន្តត្រួសត្រាយស្ថាបត្យកម្ម និងរចនាបទអប់រំថ្មីៗនៅតាមសាលាដែលខេបកំពុងធ្វើការជាមួយ។ នេះរួមមាន៖ បណ្ណាល័យសតវត្សរ៍ទី២១ ថ្នាក់រៀនទំនើប សាលប្រជុំសាលាល្អ និងមជ្ឈមណ្ឌលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅវិទ្យាស្ថានជាតិអប់រំ។ អង្គការ ខេប ពិតជាមានមោទនភាពចំពោះការបង្កើតថ្មីទាំងនេះ ហើយសង្ឃឹមថាគំរូនេះនឹងជួយអ្នករៀបចំផែនការក្រសួង និងម្ចាស់ជំនួយដទៃទៀតពិចារណាកែប្រែការរចនាបទស្តង់ដាសម្រាប់សាលារៀននៅកម្ពុជា ដែលមិនទាន់ស្របនឹងបរិបទកម្ពុជានាសតវត្សរ៍ទី២១។ អង្គការ ខេប បន្តមោទនភាពចំពោះទំនាក់ទំនងជិតស្និទ្ធជាមួយក្រសួងអប់រំ យុវជន និងកីឡា និងប្រហែលមានតែអង្គការ ខេប តែមួយប៉ុណ្ណោះ ដែលទទួលហិរញ្ញប្បទានពីក្រសួង។ បច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡាគឺជាម្ចាស់ជំនួយធំបំផុតរបស់អង្គការ ខេប ដោយបានផ្តល់ហិរញ្ញប្បទានចំនួន ១,៨ លានដុល្លារអាមេរិកក្នុងឆ្នាំសារពើពន្ធ ដើម្បីគាំទ្រដល់កំណែទម្រង់ការអប់រំសាលារៀនជំនាន់ថ្មី។

អង្គការ ខេប ក៏បានបន្តផ្តុំកម្មវិធីសុសវែរអប់រំថ្មីៗជាច្រើន ដែលស្របទៅនឹងប្រព័ន្ធសាលារៀននៅប្រទេសកម្ពុជា។ ឈ្មោះកម្មវិធីសុសវែរថ្មីដែលបង្កើតឡើងដោយអង្គការ ខេប រួមមាន៖ កម្មវិធី*អានខ្មែរ* (អំណានថ្នាក់ទី១) *សៀវភៅឆ្លាត* (អំណានអេឡិចត្រូនិចកម្រិតថ្នាក់ទី២ និង ៣) *សរសេរខ្មែរ* (សំណេរភាសាខ្មែរថ្នាក់ដំបូង) ***Literatu*** (វាយតម្លៃតាមអេឡិចត្រូនិច) *ត្រីវិស័យ* (ប្រឹក្សាអាជីពតាមអេឡិចត្រូនិច) ***X-Reading*** (ការសិក្សាភាសាអង់គ្លេស) *រឿងអប់រំ* (ការអប់រំយេនឌ័រ) *អំណានភាសាខ្មែរ* (ការវិភាគអត្ថបទ) និងកម្មវិធីថ្មីៗបំផុត គឺប្រឹក្សាគរុកោសល្យ។ កម្មវិធីសុសវែរទាំងនេះជាគោលដៅទាំងនៅកម្រិតបឋមសិក្សានិងមធ្យមសិក្សា ហើយបច្ចុប្បន្នកំពុងត្រូវបានប្រើប្រាស់ក្នុងគម្រោងជាច្រើន។ ការខិតខំទាំងនេះបានធ្វើឱ្យអង្គការ ខេប ក្លាយជាស្ថាប័នដឹកនាំគេក្នុងការអភិវឌ្ឍ និងអនុវត្តកម្មវិធីសុសវែរអប់រំបង្កើតឡើងសម្រាប់ប្រព័ន្ធសាលារៀននៅកម្ពុជា។ ការប្រើប្រាស់សុសវែរក្នុងការអប់រំគឺស្របតាមផែនការយុទ្ធសាស្ត្ររបស់អង្គការ ខេប ដើម្បីបង្កើតប្រសិទ្ធភាពក្នុងប្រតិបត្តិការអប់រំដោយប្រើប្រាស់វិសាលភាពបច្ចេកវិទ្យា។

| គម្រោងចំនួន ២០ ក្នុងឆ្នាំ២០១៩ | |
|---|---|
| Access | គម្រោងអាហារូបករណ៍ភាសាអង់គ្លេសខ្នាតតូច |
| BfC | គម្រោងសៀវភៅសម្រាប់កម្ពុជា |
| CTSP | គម្រោងអាហារូបករណ៍និស្សិតកម្រិតឧត្តមសិក្សា |
| E2L | គម្រោងងាយស្រួលរៀន * |
| FfE | គម្រោងស្បៀងអាហារសម្រាប់ការអប់រំ * |
| GEI | គម្រោងអប់រំកុមារី ** |
| HCC | គម្រោងកុមារកម្ពុជារីករាយ |
| KRP | កម្មវិធីអំណានភាសាខ្មែរ * |
| KYLA | គម្រោងសកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា |
| LSLAG | គម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី ** |
| NGPRC | មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី ** |
| NGS-SV | គម្រោងសាលារៀនជំនាន់ថ្មី/ខេត្តស្វាយរៀង |
| NGSI (Secondary) | គម្រោងសាលារៀនជំនាន់ថ្មី (កម្រិតមធ្យមសិក្សា) |
| NGSI (Primary) | គម្រោងសាលារៀនជំនាន់ថ្មី (កម្រិតបឋមសិក្សា) |
| QLE | គម្រោងបរិស្ថានសិក្សាប្រកបដោយគុណភាព |
| REACH III | គម្រោងបង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ |
| SEEK | គម្រោងពង្រឹងការអប់រំ និងអាជីពការងារ ** |
| TIGER | គម្រោងលើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងបង្រៀននិងរៀន |
| TRAC III | គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ III |
| TVP* | គម្រោងត្រីវិស័យ (Trey Visay) |
| * គម្រោងបញ្ចប់ក្នុងឆ្នាំ២០១៩; ** គម្រោងថ្មី | |



*កុមារក្នុងកម្មវិធីត្រាក់រីករាយស្តាប់រឿងនៅក្នុងបណ្ណាល័យសតវត្សរ៍ទី ២១ រៀបចំដោយអង្គការ ខេប។*

# សេចក្តីសង្ខេប

ស្ថានភាពហិរញ្ញវត្ថុទូទៅអង្គការ ខេប បានបន្តមានភាពប្រសើរឡើងក្នុងអំឡុងឆ្នាំ មានប្រាក់ចំណូលប្រចាំឆ្នាំលើសពី **៣,៥៦ លានដុល្លារអាមេរិក**ក្នុងឆ្នាំសារពើពន្ធ ២០១៨ ដល់ **៣,៧៦ លានដុល្លារអាមេរិក**ក្នុងឆ្នាំសារពើពន្ធ ២០១៩ ឬកើនឡើងចំនួន **៦%**។ នៅចុងឆ្នាំនេះ អង្គការ ខេប មានម្ចាស់ជំនួយ និងដៃគូចំនួន ១៧ រួមទាំងម្ចាស់ជំនួយថ្មីៗ ឬអតីតម្ចាស់ជំនួយ ដូចជា៖ សហគមន៍អឺរ៉ុប អង្គការ Lotus Outreach និងក្រុមហ៊ុន Gap Inc.។ ទោះបីយ៉ាងនេះក្តី ជាការកត់សម្គាល់ឃើញថាប្រាក់ចំណូលអង្គការ ខេប **៤៨,៦៣%** បច្ចុប្បន្ននេះ បានមកពីក្រសួងអប់រំ យុវជន និងកីឡា ដែលធ្វើឱ្យរាជរដ្ឋាភិបាលកម្ពុជាជាម្ចាស់ជំនួយដ៏ធំបំផុតរបស់អង្គការ ខេប។ ចំណែក **១៥,៩៦%** ទៀតគឺបានមកពីមូលនិធិឯកជន ខណៈដែលនៅមានទ្វេភាគី ឬពហុភាគី។ អត្រាប្រើប្រាស់មូលនិធិក្នុងឆ្នាំនេះមានចំនួន **៩០%** ដែលពិតជាទំហំសមតុល្យដ៏ខ្ពស់របស់អង្គការ ខេប។ ដូចនៅក្នុងឆ្នាំកន្លងមកដែរ ចំនួន **៦១%** នៃធនធានអង្គការ ខេប ត្រូវបានចំណាយទៅលើការគាំទ្ររបស់អ្នកទទួលផល រួមមាន៖ សេវាកម្មអប់រំ សម្ភារសិក្សា បរិក្ខាសាលា និងជំនួយសាលារៀន និងការសិក្សាស្រាវជ្រាវក្នុងឆ្នាំសារពើពន្ធ ២០១៩៕



*លោក ប៉ោល ហ្គោលប៊ើក ដែលបានបង្កើតកម្មវិធីអេឡិចត្រូនិច X-Reading បច្ចុប្បន្ននេះ បានជួបជាមួយសិស្សកម្ពុជាប្រើប្រាស់កម្មវិធីនេះក្នុងថ្នាក់រៀន។*


*សិស្សរីករាយនឹងសាលប្រជុំសាលារៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុន សែន កំពង់ចាម។*

## ការឆ្លុះបញ្ចាំង និងឆ្ពោះទៅមុខ...!

ដោយសារវដ្តគម្រោងមួយចំនួនគ្រោងបញ្ចប់នៅឆ្នាំ២០១៩ អង្គការ ខេប បានបន្តការវិនិយោគយ៉ាងសំខាន់លើការអភិវឌ្ឍកម្មវិធីដែលត្រូវនឹងផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំ។ ដូចនិយាយខាងលើមកហើយ អង្គការ ខេប បានផ្តោតយកចិត្តទុកដាក់ខិតខំប្រឹងប្រែងលើបញ្ហាយុវជន អក្ខរកម្មថ្នាក់ដំបូង បច្ចេកវិទ្យាក្នុងការអប់រំ និងសំខាន់បំផុតគឺការអភិវឌ្ឍសាលាធម្មនុញ្ញ។ ជារួម គម្រោងចំនួន ១៥ ត្រូវបានដាក់ស្នើជូនម្ចាស់ជំនួយពិនិត្យនិងឯកភាព។ ក្នុងចំណោមគម្រោងទាំងអស់នេះទទួលបានជោគជ័យ លើកលែងតែមួយដែលនៅរង់ចាំ (**សូមមើលមូលនិធិកាតា**)។ គម្រោងចំនួន ៩ គឺជាគម្រោងពង្រីក ខណៈពេលដែលនៅសល់គម្រោងថ្មី (SEEK, USE-SDP II, E2L/ព្រៃវែង, GEI, និង Ponlok Chamnaes) ឬបង្កើនមូលនិធិគម្រោងដែលមានស្រាប់ (LSLAG)។ ជាលទ្ធផលការខិតខំប្រឹងប្រែងអភិវឌ្ឍន៍កម្មវិធីក្នុងឆ្នាំនេះ អង្គការ ខេប រំពឹងថានឹងមានគម្រោងចំនួន ២០ នៅក្នុងឆ្នាំសារពើពន្ធបន្ទាប់។

## សេចក្តីសង្ខេបការអភិវឌ្ឍកម្មវិធីថ្មីៗក្នុងឆ្នាំ ២០១៩

| គម្រោង | ដៃគូ | ម្ចាស់ជំនួយ | លក្ខខណ្ឌ | រយៈពេល |
|---|---|---|---|---|
| 1). គម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ | អង្គការ VSO | ធនាគារអភិវឌ្ឍន៍អាស៊ី-ក្រសួងអប់រំ យុវជន និងកីឡា | ជោគជ័យ | ៣ឆ្នាំ |
| 2). គម្រោងសាលារៀនជំនាន់ថ្មី/ខេត្តស្វាយរៀង (ពង្រីក) | -- | អង្គការឆោលហ្វានកម្ពុជា | ជោគជ័យ | ៣ឆ្នាំ |
| 3). គម្រោងងាយស្រួលរៀន/ខេត្តព្រៃវែង | -- | អង្គការឆោលហ្វានកម្ពុជា | ជោគជ័យ | ៣ឆ្នាំ |
| 4). គម្រោងលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា | WeWorld-GVC<br>អង្គការ BSDA<br>ក្រុមប្រឹក្សាយុវជនកម្ពុជា | សហភាពអឺរ៉ុប | ជោគជ័យ | ៣ឆ្នាំ |
| 5). គម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី (ពង្រីកមូលនិធិ) | -- | Gap, Inc. | ជោគជ័យ | ១ឆ្នាំ |
| 6). គម្រោងកុមារកម្ពុជារីករាយ (ពង្រីក) | អង្គការគ្រួសារយើង | ក្រុមហ៊ុន គីនឆាន ស៊ីហ្វូទុង | ជោគជ័យ | ១ឆ្នាំ |
| 7). គម្រោងអប់រំកុមារី | -- | Lotus Outreach | ជោគជ័យ | ៣ឆ្នាំ |
| 8). គម្រោងសាលារៀនជំនាន់ថ្មី/កម្រិតមធ្យម (ពង្រីកដំណាក់កាលទី៤) | មូលនិធិគ្រួសារត្រកូលហ្វ្រេង | ក្រសួងអប់រំ យុវជន និងកីឡា | ជោគជ័យ | ១ឆ្នាំ |
| 9). គម្រោងសាលារៀនជំនាន់ថ្មី/កម្រិតបឋម (ពង្រីកដំណាក់កាលទី៣) | មូលនិធិគ្រួសារត្រកូលហ្វ្រេង | ក្រសួងអប់រំ យុវជន និងកីឡា | ជោគជ័យ | ១ឆ្នាំ |
| 10). មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (ពង្រីក) | អង្គការឆោលហ្វាន<br>មូលនិធិគ្រួសារត្រកូលហ្វ្រេង | ក្រសួងអប់រំ យុវជន និងកីឡា | ជោគជ័យ | ១ឆ្នាំ |
| 11). គម្រោងសកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា (ពង្រីក) | -- | អង្គការមូលនិធិអ៊ីកទ្រី | ជោគជ័យ | ១ឆ្នាំ |
| 12). គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (TRAC III) (បន្ថែម) (ពង្រីក) | -- | មូលនិធិ Phoenix | ជោគជ័យ | ២ឆ្នាំ |
| 13). គម្រោងអប់រំកុមារ (ពង្រីក) | អង្គការ Aide et Action | មូលនិធិ Qatar | នៅរង់ចាំ | ៣ឆ្នាំ |
| 14). គម្រោងសៀវភៅសម្រាប់កម្ពុជា (ពង្រីក) | -- | អង្គការមូលនិធិអាស៊ី | ជោគជ័យ | ១ឆ្នាំ |
| 15). គម្រោងពន្លកចំណេះ (Ponlok Chamnaes) | -- | អង្គការមូលនិធិអាស៊ី | ជោគជ័យ | ១ឆ្នាំ |

# ព័ត៌មាន និងព្រឹត្តិការណ៍អន្តរជាតិសំខាន់ៗ

*“ការអភិវឌ្ឍតាមរយៈបណ្តាញ និងនៅថ្នាក់មូលដ្ឋាន ”*

## តំណាងអង្គការ ខេប ជួបប្រជុំជាមួយអតីតលោកជំទាវទី១ មីឆែល អូបាម៉ា



*លោកស្រី ហ៊ឹម ម៉ារី អ្នកសម្របសម្រួលកម្មវិធីអប់រំបញ្ចូលគ្នាអង្គការ ខេប (រូបទី២ពីខាងស្តាំ)អង្គុយជាមួយលោកជំទាវ មីឆែល អូបាម៉ា ក្នុងសន្និសីទមេដឹកនាំយុវវ័យក្មេង អាស៊ី-ប៉ាស៊ីហ្វិក ក្នុងក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ខែធ្នូ ឆ្នាំ២០១៩។*

ចន្លោះថ្ងៃទី១០ ដល់ ១៤ ខែធ្នូឆ្នាំ ២០១៩ លោកស្រី ហ៊ឹម ម៉ារី អ្នកសម្របសម្រួលកម្មវិធីអប់រំបញ្ចូលគ្នាអង្គការ ខេប ត្រូវបានអញ្ជើញឱ្យចូលរួមជាមួយមេដឹកនាំវ័យក្មេង ២០០នាក់ដទៃផ្សេងទៀតមកពីតំបន់អាស៊ីប៉ា-ស៊ីហ្វិក នៅក្នុងកិច្ចប្រជុំដែលដឹកនាំដោយអតីតលោកជំទាវទី១ មីឆែល អូបាម៉ា ភរិយាប្រធានាធិបតីអាមេរិក **បារ៉ាក់ អូបាម៉ា**។ លោកស្រីមីឆែល អូបាម៉ា បានថ្លែងនៅក្នុងសន្និសិទមូលនិធិមេដឹក នាំ៖ អាស៊ី-ប៉ាស៊ីហ្វិក ជាផ្លូវការនៅទីក្រុងគូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ដែលជាផ្នែកខិតខំប្រឹងប្រែងមួយនៃមូលនិធិ ដើម្បីចាប់ផ្តើមសកម្មភាពកៀងគរយុវជន។ កិច្ចប្រជុំនេះបានផ្តោតលើគុណតម្លៃ និងការដឹកនាំប្រកបដោយក្រមសីលធម៌ និងស្វែងរកការផ្តល់សិទ្ធិអំណាចដល់មេដឹកនាំអាស៊ីវ័យក្មេងសម្រាប់ដោះស្រាយបញ្ហាប្រឈមនៅក្នុងសហគមន៍ពួកគាត់។ នេះជាលើកទី២ ដែលតំណាងអង្គការ ខេប មានឱកាសទំនាក់ទំនងជិតស្និទ្ធជាមួយលោកស្រី មីឆែល អូបាម៉ា។ ប៉ុន្មានឆ្នាំមុន នាយកប្រតិបត្តិអង្គការ ខេប បានជួបជាមួយលោកជំទាវម្តងនៅខេត្តសៀមរាបក្នុងឆ្នាំ២០១២។ អង្គការ ខេប មានកិត្តិយសដែលត្រូវជ្រើសរើសជាថ្មីម្តងទៀតក្នុងការបញ្ជូនតំណាងទៅចូលរួមព្រឹត្តិការណ៍ដែលរៀបចំឡើងដោយមូលនិធិអូបាម៉ា៕

## ការបើកសម្ពោធមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី





*រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានចូលរួមបើកសម្ពោធមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី និងសំណេះសំណាលជាមួយគរុនិស្សិត។*

នៅឆ្នាំ២០១៨ ក្រសួងអប់រំ យុវជន និងកីឡាបានស្នើសុំអង្គការ ខេប ជួយបង្កើតមជ្ឈមណ្ឌលសិក្សាជាន់ខ្ពស់នៅវិទ្យាស្ថានជាតិអប់រំ (NIE) ដែលអាចបណ្តុះបណ្តាលគ្រូប្រឹក្សាគរុកោសល្យសម្រាប់ទ្រទ្រង់សកម្មភាពអភិវឌ្ឍន៍គ្រូនៅសាលារៀនជំនាន់ថ្មី។ កិច្ចប្រឹងប្រែងនេះទទួលបានផ្លែផ្កានៅឆ្នាំ២០១៩ ដោយបានបើកសម្ពោធជាផ្លូវការអគារមជ្ឈមណ្ឌលថ្មីនៅវិទ្យាស្ថានជាតិអប់រំ។ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាបានអញ្ជើញជាអធិបតីក្នុងពិធីបើកសម្ពោធអគារមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី នៅថ្ងៃទី២១ ខែវិច្ឆិកាឆ្នាំ២០១៩ នៅរាជធានីភ្នំពេញ។ ពិធីនេះមានការចូលរួមពីមន្ត្រីជាច្រើនមកពីក្រសួងអប់រំ យុវជន និងកីឡា អង្គការឆាលហ្វានកម្ពុជា និងអង្គការនានា ព្រមទាំងបេក្ខជនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ២៥នាក់ ដែលប្រឡងជាប់ត្រូវបានចុះឈ្មោះចូលរៀនក្នុងមជ្ឈមណ្ឌល។ មជ្ឈមណ្ឌលផ្តល់នូវបរិស្ថានសិក្សាសតវត្សរ៍ទី២១ ដោយធានាបាននូវសហគមន៍គ្រូបង្រៀន និងនិស្សិតមានភាពស្និទ្ធស្នាលគ្នា មានកន្លែងទំនើបៗ និងកម្មវិធីថ្មីៗ(សុសវែរ) ដែលត្រូវបានរៀបចំដំឡើងដើម្បីលើកកម្ពស់ការបង្រៀនគ្រូប្រឹក្សាគរុកោសល្យ៕

## អង្គការ ខេប បញ្ជូនតំណាងទៅចូលរួមពិព័រណ៍ការអប់រំ និងបណ្តុះបណ្តាលបច្ចេកវិទ្យាអង់គ្លេសក្នុងប្រទេសម៉ាឡេស៊ី



ទីប្រឹក្សាជាតិជាន់ខ្ពស់អង្គការ ខេប និងដៃគូក្រុមហ៊ុនធនធានអប់រំ ឬ TTO បានចូលរួមក្នុងពិព័រណ៍ពាណិជ្ជកម្មក្នុងតំបន់ប្រចាំឆ្នាំឧបត្ថម្ភដោយវេទិកាបច្ចេកវិទ្យាអប់រំ និងបណ្តុះបណ្តាលអង់គ្លេស (BETT) នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ីនៅថ្ងៃទី ១២-១៣ ខែមីនាឆ្នាំ២០១៩។ នេះជាលើកទី៤ ហើយដែលអង្គការ ខេប បានចូលរួមព្រឹត្តិការណ៍នេះដែលជាកិច្ចខិតខំប្រឹងប្រែងដើម្បីរក្សានូវការអភិវឌ្ឍចុងក្រោយបំផុតនៃកម្មវិធីសុសវែរអប់រំ។ វត្តមានអង្គការ ខេប នៅក្នុងព្រឹត្តិការណ៍ទាំងនេះបានពង្រីកការវិនិយោគសុសវែរដែលបានប្រើនៅក្នុងសាលារៀនគាំទ្រដោយអង្គការ ខេប ដូចជា ការដាក់បញ្ចូល Literatu (ការវាយតម្លៃតាមអេឡិចត្រូនិច), Twig (សុសវែរស្តែម) និងកម្មវិធីសង្កេតការបង្រៀនថ្មីៗ (កម្មវិធីប្រឹក្សាគរុកោសល្យ)។ តាមរយៈកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអ្នកសរសេរកូដ អង្គការ ខេប អាចធ្វើឱ្យកម្មវិធីទាំងនេះមានបរិបទស្របទៅនឹងស្ថានភាពប្រទេសកម្ពុជា។ ការខិតខំប្រឹងប្រែងរបស់អង្គការ ខេប ក្នុងប្រទេសបានជួយសាលារៀនបានច្រើនក្នុងការនាំយកសេវាកម្មអប់រំពួកគាត់ឈានចូលក្នុងសតវត្សរ៍ទី២១។ វត្តមានចូលរួមក្នុងព្រឹត្តិការណ៍នេះរួមមាន៖ លោក អ៊ុល រុន (ទីប្រឹក្សាជាតិជាន់ខ្ពស់) លោក ឆន ឆៃយុទ្ធ (អ្នកសម្របសម្រួលផ្នែក ICT និងវាយតម្លៃ) លោក ម៉ៃ សារិទ្ធ (ប្រធានកម្មវិធីរីក) និងលោក ស៊ុំ វណ្ណៈ (ប្រធានគ្រប់គ្រងក្រុមហ៊ុន ធធអ)៕




## អង្គការ ខេប ប្រារព្ធខួប២០ឆ្នាំ

នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៩ អង្គការ ខេប បានចុះបញ្ជីដំបូងនៅក្រសួងមហាផ្ទៃជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក។ អង្គការ ខេប បានប្រារព្ធខួបលើកទី២០ របស់ខ្លួនផ្សាយនៅក្នុងប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក និងព្រឹត្តិការណ៍ពិសេស ដែលមានបុគ្គលិក និងអ្នកពាក់ព័ន្ធឆ្លុះបញ្ចាំងពីការងារអតីតកាល និងទិសដៅអនាគត។ ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ អង្គការ ខេប បានធ្វើការតស៊ូមតិទទួលបានការវិនិយោគជាង ៣០ លានដុល្លារអាមេរិកនៅក្នុងប្រព័ន្ធអប់រំក្នុងព្រះរាជាណាចក្រកម្ពុជា។ ដោយសារបានបំពេញការងារបង្កើតកម្មវិធីប្រកបដោយភាពច្នៃប្រឌិត និងសហការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា អង្គការ ខេប រំពឹងថានឹងចាប់ផ្តើមការងារក្នុងទសវត្សរ៍ទី៣ ដោយមានការគាំទ្រយ៉ាងខ្លាំងដល់សាលារៀន និងស្ថាប័នអប់រំនៅក្នុងព្រះរាជាណាចក្រកម្ពុជា៕

*ការចុះផ្សាយលើទំព័រកាសែតរស្មីកម្ពុជាក្នុងស្រុក និងការបោះពុម្ពផ្សាយផ្សេងៗជួយរំឭកដល់សាធារណៈជនអំពីខួបគម្រប់ ២០ឆ្នាំខេប។*

## ទីប្រឹក្សាជាតិជាន់ខ្ពស់អង្គការ ខេប ធ្វើបទបង្ហាញស្តីពីការអភិវឌ្ឍថ្មីៗនៅក្នុងសន្និបាតអាស៊ី-ប៉ាស៊ីហ្វិកស្តីពីការស្រាវជ្រាវអន្តរជាតិ( APCIR)។

នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៩ លោក អ៊ុល រុន ទីប្រឹក្សាជាតិជាន់ខ្ពស់អង្គការ ខេប និងលោកបណ្ឌិត ច័ន្ទ រ័ត្ន ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRC) នៅវិទ្យាស្ថានជាតិអប់រំ បានធ្វើបទបង្ហាញស្តីពីយុទ្ធសាស្ត្រថ្មីៗដើម្បីដោះស្រាយគុណភាពបង្រៀននៅតាមសាលារដ្ឋក្នុងសន្និបាត APCIR នៅខេត្តសៀមរាប។ NGPRC គឺជាគំនិតផ្តួចផ្តើមថ្មីរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបង្កើតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំស្ថិតក្នុងវិទ្យាស្ថានជាតិអប់រំ។ ការបង្កើតមជ្ឈមណ្ឌលគឺជាផ្នែកមួយនៃការផ្លាស់ប្តូរយុទ្ធសាស្ត្ររបស់ក្រសួងពីការចែកសិក្ខាសាលាទៅជាការបង្កើតក្របខ័ណ្ឌបង្រៀនផ្អែកលើការប្រឹក្សាគរុកោសល្យ។ កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់អប់រំគឺជាកម្មវិធីតែមួយគត់នៅអាស៊ីអាគ្នេយ៍ និងបង្ហាញពីកំណែទម្រង់ដ៏ធំមួយ ដើម្បីផ្លាស់ប្តូរធនធានបែបជាប្រឹក្សាគរុកោសល្យ។ បទបង្ហាញនេះត្រូវបានអ្នកស្រាវជ្រាវមកពីជុំវិញតំបន់អាស៊ីប៉ាស៊ីហ្វិកចាប់អារម្មណ៍ និងចាប់ផ្តើមដ៏ល្អមួយសម្រាប់ NGPRC នៅពេលចាប់ផ្តើមប្រតិបត្តិការនៅឆ្នាំដំបូង៕



*លោក អ៊ុល រុន ទីប្រឹក្សាជាតិជាន់ខ្ពស់អង្គការ ខេប ធ្វើបទបង្ហាញស្តីពីកម្មវិធីរបស់អង្គការ ខេប ក្នុងការបណ្តុះបណ្តាលគ្រូប្រឹក្សាគរុកោសល្យនៅតាមសាលា។*



↑ លោក Lord និងភរិយា Nicola (កណ្តាល) ជជែកជាមួយបុគ្គលិកអង្គការ ខេប ក្នុងបណ្ណាល័យវិ.ស៊ីសុវត្ថិ។

## អង្គការ ខេប ទទួលដំណើរទស្សនកិច្ចពី British House of Lords

ភាពល្បីល្បាញនៃសាវតាកម្មវិធីសាលារៀនជំនាន់ថ្មីនៅក្រៅប្រទេសកម្ពុជាបានបន្តធ្វើឱ្យមានការចាប់អារម្មណ៍ចំពោះអ្វីដែលអង្គការ ខេប កំពុងធ្វើនៅក្នុងវិស័យនេះ។ ដូច្នេះ ខេបបានរៀបចំទទួលដំណើរទស្សនកិច្ចលោក Lord Johnathon Mendelhsson of the House of Lords នៅសាលារៀនជំនាន់ថ្មីស៊ីសុវត្ថិនាថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩។ លោក Lord អមដំណើរដោយភរិយាគាត់ឈ្មោះ Nicola ហើយត្រូវបានតំណាងអង្គការ ខេប ទទួលស្វាគមន៍ក្នុងនាមជាអ្នកដឹកនាំកម្មវិធីសាលារៀនជំនាន់ថ្មីរបស់ក្រសួង។ លោកស្រីក៏ជាអនុប្រធានក្រុមហ៊ុន Facebook នៅអឺរ៉ុបផងដែរ និងបានចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះកិច្ចខិតខំប្រឹងប្រែងសាលារៀនជំនាន់ថ្មីក្នុងការបញ្ចូលបច្ចេកវិទ្យាទៅក្នុងការបង្រៀន។ គួរកត់សម្គាល់ផងដែរថា លោក Lord ក៏ជាសមាជិកក្រុមប្រឹក្សាភិបាលមូលនិធិគ្រួសារត្រកូលប្រៀង ដែលបានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីផ្តល់ថវិកាដល់កំណែទម្រង់ NGS។ លោក Lord ពិតជាចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះលទ្ធផលដ៏សំខាន់ដែលសម្រេចបានដោយសាលាជំនាន់ថ្មីក្នុងរយៈពេលខ្លី ហើយនឹងជួយផ្សព្វផ្សាយព័ត៌មានដល់ម្ចាស់ជំនួយដែលមានសក្តានុពលនៅក្នុងចក្រភពអង់គ្លេសអំពីកំណែទម្រង់គួរឱ្យកត់សម្គាល់នៅក្នុងវិស័យអប់រំនៅកម្ពុជា៕

## សមាជិកសភាបានចុះធ្វើទស្សនកិច្ចសិក្សានៅសាលារៀនជំនាន់ថ្មី



ឯកឧត្តម ហ៊ុន ម៉ានី ប្រធានគណៈកម្មាធិការទី៧ សម្រាប់កិច្ចការអប់រំ យុវជន កីឡា សាសនា វប្បធម៌ និងទេសចរណ៍ បានទស្សនកិច្ចសិក្សានៅបន្ទប់សិស្សរៀនផ្ទាល់នៅសាលារៀនជំនាន់ថ្មី គោកព្រីង ក្នុងខេត្តស្វាយរៀង

អង្គការ ខេប និងអង្គការឆាលហ្វាន កម្ពុជា បានធ្វើការសហការយ៉ាងជិតស្និទ្ធ ដើម្បីបន្តធ្វើការអនុវត្តនូវកំណែទម្រង់កម្មវិធីសាលាជំនាន់ថ្មី តាមតំបន់ជនបទនៃប្រទេសកម្ពុជា ដូចជា នៅខេត្តស្វាយរៀង។ ជោគជ័យនៃកិច្ចខិតខំប្រឹងប្រែងទាំងនេះ បាននាំឱ្យមានដំណើរទស្សនកិច្ចដ៏ខ្ពង់ខ្ពស់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា។ ឯកឧត្តមប្រធាន និងសមាជិកគណៈកម្មាធិការទី៧ នៃរដ្ឋសភាបានធ្វើទស្សនកិច្ចនៅអនុវិទ្យាល័យគោកព្រីង និងសាលាបឋមសិក្សាស្វាយព្រហូត នៅខេត្តស្វាយរៀង នាថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៩។ សាលាទាំងពីរគឺជាសាលាអនុវត្តនូវកម្មវិធីសាលាជំនាន់ថ្មី ដែលជាផ្នែកមួយនៃកំណែទម្រង់ការអប់រំតាមរយៈការផ្ដួចផ្ដើមដោយក្រសួងអប់រំ យុវជន និងកីឡា។ ប្រតិភូសភាដែលត្រូវបានដឹកនាំដោយឯកឧត្តម ហ៊ុន ម៉ានី ជាប្រធានគណៈកម្មាធិការទី៧ បានសម្ដែងនូវការគាំទ្រយ៉ាងខ្លាំងចំពោះកំណែទម្រង់នេះ ហើយមានការចាប់អារម្មណ៍ទៅលើសកម្មភាពមួយចំនួន ដូចជា ស្នាដៃសកម្មភាពសិស្សតាមគម្រោង ការប្រើប្រាស់បច្ចេកវិទ្យា ICT សម្រាប់ការអប់រំ និងគ្រឿងបរិក្ខារបែបសតវត្សរ៍ទី២១។ ប្រតិភូសភាដែលបានធ្វើទស្សនកិច្ចទទួលស្គាល់តម្រូវការសម្រាប់កំណែទម្រង់ ដូចជា សាលារៀនជំនាន់ថ្មី ប៉ុន្តែក៏បានផ្ដល់ដំបូន្មានល្អផងដែរថាកំណែទម្រង់កម្មវិធីសាលាជំនាន់ថ្មីគួរតែដំណើរការដោយប្រុងប្រយ័ត្នពីព្រោះអ្នកអប់រំ និងសាធារណៈជនជាច្រើននៅមិនទាន់យល់ច្បាស់អំពីកំណែទម្រង់នេះទេពីព្រោះវាជាកម្មវិធីថ្មីនៅកម្ពុជា។ ទោះយ៉ាងណាក៏ដោយ ដំណើរទស្សនកិច្ចនេះគឺជាការជំរុញដ៏ល្អមួយសម្រាប់គាំទ្រកំណែទម្រង់សាលារៀនជំនាន់ថ្មី និងបន្តរក្សាការអនុវត្តឱ្យបានចិតថេរ៕

## ការចូលរួមកម្មវិធី UNLEASH

នៅឆ្នាំនេះ លោក ឆន ឆៃយុទ្ធ សមាជិកថ្នាក់គ្រប់គ្រងជាន់ខ្ពស់អង្គការ ខេប ត្រូវបានជ្រើសរើសចេញពីចំណោមអ្នកដាក់ពាក្យសុំជាអន្តរជាតិប្រមាណជាង ៨.០០០នាក់ ដើម្បីក្លាយជា Global Talent និងជាតំណាងរបស់កម្ពុជាដើម្បីចូលរួមកម្មវិធី #UNLEASH2019 នៅទីក្រុងសិនជិន ប្រទេសចិន។ ព្រឹត្តិការណ៍នេះបានធ្វើឡើងនៅថ្ងៃទី ៦-១៣ ខែវិច្ឆិកាឆ្នាំ២០១៩។ លោក ឆៃយុទ្ធ មានឱកាសធ្វើការជាមួយអ្នកចូលរួម១.០០០នាក់ ផ្សេងទៀតមកពី១៥២ប្រទេស ដើម្បីបង្កើតដំណោះស្រាយ និងភាពច្នៃប្រឌិតថ្មីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព( SDG)។ ក្នុងអំឡុងពេលសិក្ខាសាលា លោក ឆៃយុទ្ធ បានធ្វើការជាមួយក្រុមរបស់លោកលើការបង្កើតកម្មវិធីជជែកវៃឆ្លាតដោយប្រើបញ្ញាសិប្បនិម្មិតដែលនឹងជួយគាំទ្រដល់ការអប់រំសុខភាពផ្លូវចិត្តសម្រាប់កុមារីយក្មេងនៅក្នុងប្រទេសនីហ្សេរីយ៉ា៕



រូបភាពក្រុមលោក ឆៃយុទ្ធ (រូបទី២ពីស្ដាំ) និងសមាជិកក្រុមមានទេពកោសល្យសកល ដែលបានធ្វើការផ្ដោត SDG4 លើប្រធានបទ ICT ក្នុងការអប់រំ។




## ការបង្ហាញរូបរាងថ្មី និងបច្ចុប្បន្នភាពកម្មវិធីត្រីវិស័យ

ត្រីវិស័យ (ឬ "Compass/ត្រីវិស័យ" ជាភាសាអង់គ្លេស) គឺជាកម្មវិធីប្រឹក្សាតាមទូរសព្ទអេឡិចត្រូនិច ដែលអនុញ្ញាតឱ្យសិស្សានុសិស្សធ្វើស្វ័យវាយតម្លៃខ្លួនឯង និងស្វែងរកព័ត៌មានអំពីគ្រឹះស្ថានអប់រំ និងជម្រើសអាជីពការងារ ដើម្បីត្រៀមខ្លួនរៀបចំផែនការសម្រាប់ពេលអនាគត។ កម្មវិធីនេះត្រូវបានធ្វើបច្ចុប្បន្នភាពដោយអង្គការ ខេប និងដៃគូរបស់ខ្លួនគឺអង្គការ InSTEDD បានដាក់បង្ហាញខ្លួនថ្មីនៅខែកុម្ភៈ ឆ្នាំ២០១៩។ កម្មវិធីនេះជួយសាលារៀននៅកម្ពុជាដោះស្រាយបញ្ហាអវត្តមានអ្នកប្រឹក្សាយោបល់ដោយប្រើប្រាស់ដំណោះស្រាយបែបបច្ចេកវិទ្យាជួយយុវជនកម្ពុជាធ្វើការសម្រេចចិត្តផ្អែកលើព័ត៌មានស្ដីពីអនាគតពួកគាត់។ ក្នុងបច្ចុប្បន្ននេះ កម្មវិធីត្រីវិស័យអាចទាញយកបានពី App Store និង Google Play store។ សូមវាយតាមតំណរភ្ជាប់ខាងក្រោមដើម្បីទាញយកកម្មវិធីជំនាន់ចុងក្រោយ៕

**App Store:** https://itunes.apple.com/kh/app/trey-visay/id1445506569?mt=8
**Google Play Store:** https://play.google.com/store/apps/details?=com.treyvisay

## សាលារៀនធម្មនុញ្ញកម្ពុជា៖ ការសម្រេចបាននូវវត្តមានលើឆាកអន្តរជាតិសម្រាប់ការងារអង្គការ ខេប លើកម្មវិធីសាលារៀនជំនាន់ថ្មី

កំណែទម្រង់នៃកម្មវិធីសាលារៀនជំនាន់ថ្មី(NGS) ជារបកគំហើញដ៏សំខាន់បំផុតមួយរបស់អង្គការ ខេប ក្នុងការបន្តលើកកម្ពស់ស្តង់ដាអប់រំឱ្យកាន់តែប្រសើរឡើងនៅតាមសាលារដ្ឋនៅក្នុងប្រទេសកម្ពុជា។ បើទោះជាមានគ្រូអភិរក្សនិយមមួយចំនួនតូចជំទាស់នឹងកំណែទម្រង់អប់រំនេះ និងកំពុងរារាំងប្រឆាំងនឹងកម្មវិធីសាលារៀនជំនាន់ថ្មីក៏ដោយ ក៏គំរូដ៏ល្អនេះនៅតែបន្តធ្វើឱ្យអ្នកអប់រំនៅទូទាំងពិភពលោកចាប់អារម្មណ៍យ៉ាងខ្លាំង។ នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៩ បទបង្ហាញមួយត្រូវបានធ្វើឡើងស្តីពីភាពជោគជ័យរបស់កម្មវិធីសាលាជំនាន់ថ្មីនៅឯវេទិកាអប់រំសកលនៅទីក្រុងបូស្តុន ដែលរៀបចំឡើងដោយសាលា the Harvard Graduate School of Education។ បទបង្ហាញមួយទៀតស្តីពីកម្មវិធីសាលារៀនជំនាន់ថ្មីត្រូវបានធ្វើឡើងនៅក្នុងសន្និសីទស្តីពី**សង្គមប្រៀបធៀប និងការអប់រំជាអន្តរជាតិ** នៅទីក្រុងសាន់ហ្វ្រាន់ស៊ីស្កូ នៅខែមេសា ឆ្នាំ២០១៩។ លើសពីនេះទៀត សាស្ត្រាចារ្យ ហារើដ ហ្វីណាន់ដូ រ៉មើស ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ នឹងបញ្ចូលជំពូកមួយស្តីពីកំណែទម្រង់សាលារៀនជំនាន់ថ្មីនៅក្នុងសៀវភៅរបស់គាត់នាពេលខាងមុខ និងមានការបោះពុម្ពផ្សាយមួយផ្សេងទៀតដែលដាក់ឈ្មោះថា "**ការអប់រំនៅកម្ពុជា៖** ចាប់ពីឆ្នាំសូន្យទៅដល់ស្តង់ដាអន្តរជាតិ "(បោះពុម្ពផ្សាយដោយ Springer)។ នៅក្នុងព័ត៌មានផ្សេងទៀត ប្រទេសឡាវក៏គ្រោងនឹងធ្វើការចម្លងគំរូកម្មវិធីសាលារៀនជំនាន់ថ្មីនេះសម្រាប់អនុវត្តនៅក្នុងប្រទេសខ្លួនផងដែរ ដោយមានការគាំទ្រពីមូលនិធិគ្រួសារត្រកូលហ្វ្រេង។ ទីបំផុត ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ ខេប បានផលិតវីដេអូផ្សព្វផ្សាយពីកម្មវិធីសាលារៀនជំនាន់ថ្មីក្នុងគោលបំណងបង្ហាញ និងណែនាំដល់សាធារណជនកម្ពុជាអំពីគោលដៅ និងវត្ថុបំណងកំណែទម្រង់ក្នុងកម្មវិធីសាលារៀនជំនាន់ថ្មីដើម្បីបង្កើនការទទួលស្គាល់ និងការយល់ដឹងអំពីគំរូនេះ (ឧ. https://youtu.be/QXfTAR1Y6FU)។ ការបង្កើតវីដេអូណែនាំនេះត្រូវបានឧបត្ថម្ភរួមគ្នាដោយក្រសួងអប់រំ យុវជន និងកីឡា និងមូលនិធិគ្រួសារត្រកូលហ្វ្រេង។ ជាមួយនឹងការទទួលស្គាល់ទាំងអស់នេះក្រសួងអប់រំ យុវជន និងកីឡាត្រូវបានទទួលការអបអរសាទរជាថ្មីម្តងទៀតចំពោះការលើកកម្ពស់កំណែទម្រង់ការអប់រំថ្មីដ៏គួរឱ្យរំភើប។




## ការចេញផ្សាយនូវអត្ថបទស្រាវជ្រាវរបស់អង្គការ ខេប នៅក្នុងទស្សនាវដ្តី the Journal of Modern Education Review



Journal of Modern Education Review, ISSN 2155-7993, USA
March 2018, Volume 8, No. 3, pp. 178-191
Doi: 10.15341/jmer(2155-7993)/03.08.2018/002
©Academic Star Publishing Company, 2018
http://www.academicstar.us

Academic Star

**The Impact of Holistic Educational Programs on Quality and Learning Outcomes in Cambodia**

Pisseth Hang[1], Daro Khorn[1], Steven Prigent[2], Kaongyou Yuth[1]
(1. Kampuchean Action for Primary Education, Cambodia; 2. School for Advanced Studies of the Social Sciences, Paris, France)

**Abstract:** Since 2013, Save the Children International, funded by the Norwegian Government (NORAD), has been implementing a four years' educational pilot program called "I'm Learning!" in 15 rural primary schools in Cambodia. This holistic program is based on four main Quality Learning Environment (QLE) guiding principles (GP): emotional and psychosocial protection; physical protection; teaching learning environment (active learning); collaboration between schools and parents/community. In order to validate the value of the QLE framework using evidence-based methodologies, Save the Children Norway (SCN) and Save the Children International (SCI) in Cambodia engaged an independent local NGO — Kampuchean Action for Primary Education (KAPE) — to design and conduct a research study to assess the relationship between SC interventions according to the QLE GP and learning outcomes during the last three years of the four year pilot.

The research is based on four schools out of fifteen in which SCI undertook interventions. Four other schools where no SCI interventions took place were selected for comparative purposes. The research is based on qualitative and quantitative data collected over three school years, 2014-2017. The paper will show that "I'm Learning!" really made a difference in reading skills, and that although it is not possible to prove a clear relationship between QLE GP and student learning outcomes, three main improvements lead to better student learning outcomes in the framework of "I'm Learning!", namely community-based monitoring, positive discipline and enriched teaching methods.

**Key words:** holistic educational programs, quality learning environment (QLE), learning outcomes, Cambodia

**1. Introduction**

In spite of recent successes in its educational development mainly with respect to access, Cambodia's education system still ranks among the worst in Southeast Asia, particularly with regards to educational quality.

178

នៅចន្លោះឆ្នាំ២០១៣ និងឆ្នាំ២០១៧ អង្គការ ខេប ទទួលបានថវិកាពីអង្គការ Save the Children និង NORAD ដើម្បីស៊ើបអង្កេតពីផលប៉ះពាល់នៃវិធីសាស្ត្រចម្រុះក្នុងការអប់រំលើគុណភាពអប់រំ។ ការស៊ើបអង្កេតនេះត្រូវបានបង្កើតឡើងជាការសិក្សាស្រាវជ្រាវផ្លូវការមួយដែលត្រូវបានបោះពុម្ពផ្សាយជាអត្ថបទត្រូវបានពិនិត្យឡើងវិញដោយមិត្តនៅក្នុងទស្សនាវដ្តីត្រួតពិនិត្យការអប់រំទំនើប។ អត្ថបទស្រាវជ្រាវនេះមានចំណងជើងថា ផលជះនៃកម្មវិធីអប់រំចម្រុះស្តីពីគុណភាព និងលទ្ធផលសិក្សានៅកម្ពុជា cf. http://kapekh.org/files/report_file/105-en.pdf ។ ឯកសារបានបង្ហាញថាកម្មវិធីចម្រុះដែលគាំទ្រដោយអង្គការ ខេប និង Save the Children ពិតជាបានធ្វើឱ្យមានភាពខុសប្លែកគ្នាលើបំណិនអានហើយទោះបីវាមិនអាចបង្ហាញពីទំនាក់ទំនងច្បាស់លាស់រវាងក្របខ័ណ្ឌទាំងមូលដែលបង្កើតឡើងដោយ Save the Children ដែលត្រូវបានគេស្គាល់ថាជាបរិស្ថានសិក្សាប្រកបគុណភាព(QLE)និងលទ្ធផលសិក្សារបស់សិស្ស ការកែលម្អសំខាន់ៗចំនួនបីនាំឱ្យលទ្ធផលសិក្សាសិស្សកាន់តែប្រសើរឡើងនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីដែលត្រូវបានគាំទ្រ ពោលគឺការឃ្លាំមើលនៅតាមសហគមន៍វិន័យវិជ្ជមាន និងវិធីសាស្ត្របង្រៀនដែលបានពង្រឹង។ ឯកសារស្រាវជ្រាវនេះត្រូវបាននិពន្ធដោយបុគ្គលិកអង្គការ ខេប ចំនួន៤រូបរួមមាន៖ លោកបណ្ឌិត ស្ទីវិន ព្រីងជិន លោក ហង្ស ពិសិដ្ឋ លោក ខន ដារូ និងលោក យុទ្ធ គង់យូ។



*ការគាំទ្រសំខាន់៖ សម្តេចនាយករដ្ឋមន្ត្រីបានផ្តល់ការគាំទ្រជាសាធារណៈ ចំពោះសាលារៀនជំនាន់ថ្មីនៅក្នុងពិធីចែកសញ្ញាបត្រនៅរាជធានីភ្នំពេញ។*

## សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ផ្តល់ការគាំទ្រដល់សាលារៀនជំនាន់ថ្មី

ថ្លែងនៅក្នុងពិធីចែកសញ្ញាបត្រនៅសាលាប៊ែលធីអន្តរជាតិក្នុងរាជធានីភ្នំពេញ សម្តេច ហ៊ុន សែន បានផ្តល់អនុសាសន៍គួរឱ្យកត់សម្គាល់ដល់វិស័យសាលាឯកជន ដើម្បីពិចារណាលើភាពជោគជ័យ និងកម្មវិធីច្នៃប្រឌិតថ្មីៗដែលសម្រេចបានដោយប្រព័ន្ធអប់រំសាលារៀនជំនាន់ថ្មី។ នេះគឺជាការគាំទ្រយ៉ាងពេញទំហឹងចំពោះអ្វីៗដែលសម្រេចបានដោយសាលារៀនជំនាន់ថ្មី និងជាការបង្ហាញអំពីចក្ខុវិស័យដ៏វែងឆ្ងាយរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា៕

## អង្គការ ខេប ត្រូវបានផ្សព្វផ្សាយលើកញ្ចក់ទូរទស្សន៍របស់ប្រទេសថៃ

ជាច្រើនឆ្នាំកន្លងទៅ អង្គការ ខេប បានធ្វើទស្សនកិច្ចប្រចាំឆ្នាំនៅតាមគ្រឹះស្ថានអប់រំនានាក្នុងប្រទេសថៃ ដើម្បីរៀនពីបទពិសោធន៍អន្តរជាតិនៅក្នុងតំបន់សម្រាប់ជួយដល់អ្នកអប់រំកម្ពុជាដើម្បីលើកកម្ពស់ប្រព័ន្ធអប់រំនៅកម្ពុជា។ សាលាមួយក្នុងចំណោមសាលារៀនដែលត្រូវបានទៅទស្សនកិច្ចច្រើនជាងគេគឺវិទ្យាល័យ Lamplaimat Pathana នៅខេត្តបុរីរាមប្រទេសថៃ។ សាលានេះមានភាពល្បីល្បាញនៅប្រទេសថៃជាគំរូអប់រំពិសោធន៍នៅក្នុងតំបន់ជនបទ ដែលមានលទ្ធផលតេស្តខ្ពស់បំផុតលើការប្រឡងថ្នាក់ជាតិ ប៉ុន្តែមិនទាន់មានការចុះឈ្មោះចូលរៀន ការធ្វើតេស្តនៅតាមថ្នាក់ ឬវិន័យក្រៅសាលាទេ។ សាលាធ្វើឱ្យមានការគ្រប់គ្រងវិន័យដោយការកោតសរសើរក្មេងៗនៅកម្រិតមត្តេយ្យ ដើម្បីឱ្យពួកគេរៀនគ្រប់គ្រងឥរិយាបថតាំងពីក្មេងដោយមិនចាំបាច់មានវិន័យតិចតួច ឬគ្មានពីខាងក្រៅ។ ដូច្នេះ ក្មេងៗរៀនដោយគ្មានការភ័យខ្លាច ដែលជាគំនិតវិវឌ្ឍន៍សម្រាប់អ្នកអប់រំកម្ពុជា។ អង្គការ ខេប បានបញ្ជូនអ្នកអប់រំកម្ពុជាប្រមាណ ៨០នាក់ មកកាន់សាលានេះជារៀងរាល់ឆ្នាំ ដោយធ្វើដំណើរតាមឡានក្រុងដើម្បីសន្សំសំចៃ។ បច្ចុប្បន្ននេះ គ្រូនិងគណៈគ្រប់គ្រងសាលាកម្ពុជាជាង ៣៥០នាក់ មានបទពិសោធន៍ពីអន្តរជាតិ ដែលមានការចាក់ផ្សាយតាមកញ្ចក់ទូរទស្សន៍ពិសេសរបស់ថៃអំពីការសហការគ្នារវាងអ្នកអប់រំកម្ពុជានិងថៃ។ កម្មវិធី Thai PBS ដែលមានឈ្មោះថា Chab Ta ឬ Eye-Catchers បានចាក់ផ្សាយកម្មវិធីនេះនៅឆ្នាំ២០១៩។ សូមទស្សនានៅលើតំណភ្ជាប់ដែលបានផ្តល់ជូនខាងក្រោម។






*អ្នកអប់រំកម្ពុជាបានទៅទស្សនកិច្ចនៅសាលា Lamplainmat នៅប្រទេសថៃ (ខាងលើ) កម្មវិធី PBS ចាក់ផ្សាយអំពីកិច្ចសហការដឹកនាំដោយអង្គការ ខេប ជាមួយអ្នកអប់រំថៃ (ខាងក្រោម)។*

https://drive.google.com/file/d/1Uz9DrDJg1VYdg2iGkQf7IRc7gpLN5J0W/view?fbclid=IwAR163iyTvJ4j3K1lIh4mwDU04CmsfH7IqIm 8WweL591APFmmtfdtJbTmiiA

# ធីធីអូ អ៊ីមផត អិចផត ឯ.ក

*“សម្ភារៈជំនួយការសិក្សាដែលមានប្រសិទ្ធភាព និងតម្លៃសមរម្យ”*



ការងារទីផ្សារ ពិព័រណ៍សៀវភៅថ្នាក់ជាតិឆ្នាំ២០១៩ និងការលក់

## សេចក្ដីសង្ខេប

### អំពីយើង

ធីធីអូជាក្រុមហ៊ុនក្នុងស្រុក ផលិតនិងចែកចាយសម្ភារបង្រៀននិងរៀនទាំងក្នុងនិងក្រៅថ្នាក់។

### ផលិតផល

សម្ភារបង្រៀនរួមមាន៖

- ល្បែងសិក្សាគណិតវិទ្យា២៤
- ល្បែងសិក្សាភាសា ៣២
- ល្បែងសិក្សាវិទ្យាសាស្ត្រ ២
- ទម្រង់វាយតម្លៃអំណាន ៣ កម្រិត

### ទទួលស្គាល់

ផលិតផលទទួលស្គាល់ និងបានប្រកាសអនុញ្ញាតបោះពុម្ពផ្សាយ ដោយក្រសួងអប់រំ យុវជននិងកីឡា។





ការងាររៀបចំបង្កើតរចនាបទស្លាបត្យកម្មថ្មី។



វគ្គតម្រង់ទិសស្ដីពីការប្រើប្រាស់សម្ភារបង្រៀន និងរៀន



← ការចូលរួមក្នុងសង្គម៖ ធីធីអូបានសហការជាមួយដៃគូអង្គការជួយសាលារៀនអភិវឌ្ឍន៍គុណភាពបរិស្ថានសិក្សា។



ការងារចែកចាយ និងលក់ផលិតផល

ព័ត៌មានលម្អិតបន្ថែមនៅលើគេហទំព័រធនធានអប់រំ: **www.tts-kape.org** និងចុច “**Like**” និងចុច “**Share**” បណ្ដាញសង្គម Facebook របស់យើង: www.facebook.com/ttskape។

# គម្រោង សាលារៀនជំនាន់ថ្មី (NGS)

*" ជាសាលាជម្នាញនាំមុខបំផុតនៅក្នុងប្រទេសកម្ពុជា "*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | ក្រសួងអប់រំ យុវជន និងកីឡា<br>មូលនិធិគ្រួសារត្រកូលហ្ស៊ែង |
| អ្នកទទួលផលផ្ទាល់ | សិស្សមធ្យម ៣.៤៥០នាក់<br>សិស្សបឋម ១.៦៣៥នាក់<br>**សិស្សសរុប ៥.០៨៥នាក់** |
| ថវិកាទទួលបានក្នុងឆ្នាំ២០១៩ | ១,៦ លានដុល្លារអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផល | ៣១៤ ដុល្លារអាមេរិក/១នាក់ |
| ខេត្តគ្របដណ្តប់ | ៤ (ភ្នំពេញ កំពង់ចាម កំពង់ស្ពឺ និងកណ្តាល) |
| ចំនួនស្រុកគ្របដណ្តប់ | ៦ |
| មធ្យមសិក្សាគោលដៅ | ៥ |
| បឋមសិក្សាគោលដៅ | ៣ |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ខែតុលា ឆ្នាំ២០១៥ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | មិនកំណត់ |

## បច្ចុប្បន្នភាពគម្រោង

កម្មវិធីសាលារៀនជំនាន់ថ្មីបានបញ្ចប់ឆ្នាំទី៤ គាំទ្រផ្នែកហិរញ្ញប្បទានដោយក្រសួងអប់រំ យុវជន និងកីឡា ហើយអង្គការ ខេប បានដើរតួជាប្រតិបត្តិករ។ សាលារៀនជំនាន់ថ្មីចំនួន ១០ ដែលត្រូវបានគាំទ្រក្នុងឆ្នាំនេះ (សាលារៀន ៨ គាំទ្រថវិកាដោយក្រសួងអប់រំ យុវជន និងកីឡា និងមូលនិធិគ្រួសារត្រកូលហ្ស៊ែង ហើយសាលារៀនចំនួន ២ គាំទ្រថវិកាដោយអង្គការឆាលហ្វានកម្ពុជា)។ ការគាំទ្រសាលារៀនខ្លះទៀតបានបន្តពង្រីកចំនួនថ្នាក់ដែលគាំទ្រដោយការវិនិយោគរបស់ NGS មានការកើនឡើងជាលំដាប់បណ្តាលឱ្យកើនការគាំទ្រកម្មវិធីរបស់សាលារៀនទាំងមូល។ នេះរួមបញ្ចូលទាំងការវិនិយោគនៅវិទ្យាល័យព្រែកលៀប វិទ្យាល័យសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ព្រែកអញ្ចាញ វិទ្យាល័យ ហ៊ុន សែន ពាមជីកង ក៏ដូចជាសាលាបឋមសិក្សាព្រះរាជអគ្គមហេសី នរោត្តមមុនីនាថ សីហនុ។ តម្រូវការក្នុងការចូលសាលារៀនជំនាន់ថ្មីបានផ្ទុះឡើង ហើយលើសពីកន្លែងដែលមាន នេះបង្ហាញពីស្តង់ដាគុណភាពខ្ពស់នៃសាលារៀនទាំងនេះ និងការទទួលស្គាល់គុណភាពពីសាធារណៈជនទូទៅ។

## ព្រឹត្តការណ៍សំខាន់ៗ

- **ការទទួលស្គាល់ថ្នាក់ជាតិ៖** រាជរដ្ឋាភិបាលកម្ពុជាបានដាក់បញ្ចូលកម្មវិធីសាលាជំនាន់ថ្មីជាផ្លូវការនៅក្នុងផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ អាណត្តិទី៦ ដែលបានទទួលស្គាល់ពីថ្នាក់ជាតិនៃការកែទម្រង់សាលារៀនជំនាន់ថ្មីក្នុងកម្រិតខ្ពស់បំផុត។
- **ការកើនឡើងសាលារៀនជំនាន់ថ្មីដែលបានវាយតម្លៃទទួលស្គាល់គុណភាពអប់រំ៖** ចំនួនសាលារៀនជំនាន់ថ្មីដែលមានការទទួលស្គាល់ជាផ្លូវការបានកើនឡើងពី ២ ដល់ ៤ ដែលមានវិទ្យាល័យព្រះស៊ីសុវត្ថិ វិទ្យាល័យ ហ៊ុន សែន កំពង់ចាម ឥឡូវនេះមានវិទ្យាល័យគោកព្រីង និងសាលាបឋមសិក្សាអនុវត្ត ហ៊ុន សែន ខេត្តកំពង់ចាម។
- **លទ្ធផលដ៏វិសេសនៃការប្រឡងថ្នាក់ជាតិ៖** សិស្សានុសិស្សវិទ្យាល័យព្រះស៊ីសុវត្ថិ និងវិទ្យាល័យ ហ៊ុន សែន កំពង់ចាម បានទទួលលទ្ធផលលើសពីមធ្យមភាគថ្នាក់ជាតិ (៦៨%) ជាមួយនឹងអត្រាជាប់ ៩៤% នៅវិទ្យាល័យព្រះស៊ីសុវត្ថិ និងអត្រាជាប់ ៨៤% នៅវិទ្យាល័យ ហ៊ុន សែន កំពង់ចាម។
- **ពានរង្វាន់អន្តរជាតិ៖** សាលារៀនជំនាន់ថ្មីទទួលបាន ៤២៤ មេដាយទាំងមេដាយមាស មេដាយប្រាក់ និងសំរិទ្ធនៅក្នុងឆ្នាំនេះ។
- **ការពង្រីកកម្មវិធីសាលារៀនជំនាន់ថ្មីនៅក្នុងវិទ្យាស្ថានជាតិអប់រំ៖** ក្រសួងអប់រំ យុវជន និងកីឡា បានស្នើឱ្យអង្គការ ខេប បង្កើតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំសម្រាប់បណ្តុះបណ្តាលគ្រូប្រឹក្សាគរុកោសល្យនៅវិទ្យាស្ថានជាតិអប់រំ។ មជ្ឈមណ្ឌលថ្មីមួយត្រូវបានបើកនៅវិទ្យាស្ថានជាតិអប់រំក្នុងខែកញ្ញា ឆ្នាំ ២០១៩។

## សនិទានភាពកម្មវិធី

កម្មវិធីសាលារៀនជំនាន់ថ្មីសំដៅទៅកាន់កម្មវិធីកំណែទម្រង់អប់រំ ដោយក្រសួងអប់រំ យុវជន និងកីឡានៅឆ្នាំ២០១៥ ដើម្បីបង្កើតសាលារៀនសាធារណៈ"**ស្វយ័ត**"មួយមានសិទ្ធិច្នៃប្រឌិត និងកែលម្អគុណភាពអប់រំ។ សាលារៀនជំនាន់ថ្មីមានបុព្វសិទ្ធិទទួលបានមូលនិធិវិនិយោគខ្ពស់គឺអាស្រ័យលើស្តង់ដារវិជ្ជាជីវៈខ្ពស់ និងអភិបាលកិច្ចល្អ។ គន្លងអភិវឌ្ឍន៍ថ្មីនេះព្យាយាមជំរុញគ្រឹះស្ថានអប់រំសាធារណៈឱ្យឈានកម្រិតខ្ពស់មួយទៀតដើម្បីសម្រេចបានស្តង់ដាអប់រំអតិបរិមា ជាពិសេសចំពោះមុខវិជ្ជាស្ទែម(STEM)។ ស្ថិតក្រោមគោលនយោបាយថ្មីដែលបានកំណត់និយមន័យសាលារៀនជំនាន់ថ្មី ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការប្តេជ្ញាខ្លាំងក្នុងការវិនិយោគប្រកបដោយប្រសិទ្ធភាពដល់សាលារៀនបែបនេះក្រោមលក្ខខណ្ឌដែលធានាបាននូវស្តង់ដាខ្ពស់ និងអភិបាលកិច្ចល្អ។ ដោយមានប្រព័ន្ធវាយតម្លៃទទួលស្គាល់គុណភាពអប់រំតឹងរ៉ឹងផ្សារភ្ជាប់នឹងការវិនិយោគបន្ត គោលនយោបាយថ្មីបានលើកទឹកចិត្តសាលារៀនឱ្យប្រកាន់ភ្ជាប់នូវបទដ្ឋានអប់រំខ្ពស់។ សាលារៀនជំនាន់ថ្មីអនុវត្តតាមគំរូនានាពីប្រទេសផ្សេងៗ ដែលសាលារៀនរដ្ឋមួយចំនួនទទួលបានស្វ័យភាពពេញលេញពីរដ្ឋក្នុងការច្នៃប្រឌិតកម្មវិធីអប់រំរបស់ខ្លួន។ នេះនិយាយជាពិសេសសំដៅលើ "**សាលារៀនជម្នាញ**" ឬ Charter School Movement នៅសហរដ្ឋអាមេរិក និងប្រទេសដទៃទៀត។ ក្រសួងអប់រំ យុវជន និងកីឡា មានគោលបំណងបង្កើតសាលារៀនជំនាន់ថ្មីយ៉ាងតិចចំនួន ៥០ នៅក្នុងរយៈពេល១០ឆ្នាំខាងមុខ។

## សកម្មភាពសំខាន់ៗ

- ការពង្រីកកំណែទម្រង់សាលារៀនជំនាន់ថ្មីទៅកម្រិតឧត្តមសិក្សា ដែលបង្កើតឡើងដោយប្រើសម្ភារបរិក្ខារសាលារៀនជំនាន់ថ្មី នៅវិទ្យាស្ថានជាតិអប់រំ (សូមមើលខាងក្រោម)។
- ការបង្កើតឯកសារបណ្តុះបណ្តាលថ្មីមួយនៅក្នុងបណ្ណាល័យបែបសតវត្សទី២១ និងឯកសារវាយតម្លៃសិស្ស។
- ការវាយតម្លៃទទួលស្គាល់គុណភាពអប់រំ សាលារៀនជំនាន់ថ្មីចំនួន៤ គឺ៖ (វិ. ព្រះស៊ីសុវត្ថិ វិ. ហ៊ុន សែន កំពង់ចាម វិ. គោកព្រីង និងបឋម. អនុវត្ត ហ៊ុន សែន)។
- ការបញ្ចប់ការដំឡើងសម្ភារៈ និងគ្រឿងសង្ហារឹមចំនួន៣៦មុខ រួមមាន៖ ថ្នាក់រៀន បន្ទប់ពិសោធន៍ បណ្ណាល័យសតវត្សទី២១ ក្លឹបសិស្ស មណ្ឌលយុវជន និងសាលប្រជុំ។





**មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីបានបើកនៅក្នុងវិទ្យាស្ថានជាតិអប់រំ៖** តាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា អង្គការ ខេប បានសាងសង់លើអគារចាស់ទ្រុឌទ្រោមឡើងវិញ ហើយបានបំពាក់សម្ភារៈបរិក្ខាអប់រំទំនើបៗនៅក្នុងវិទ្យាស្ថានជាតិអប់រំ ដែលនឹងផ្តល់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់លើឯកទេសគ្រូប្រឹក្សាគរុកោសល្យ ដើម្បីសម្របសម្រួលធ្វើយ៉ាងណាឱ្យមាននិរន្តរភាព និងការពង្រីកកម្មវិធីសាលារៀនជំនាន់ថ្មី។ មជ្ឈមណ្ឌលមានបន្ទប់ប្រជុំ និងបន្ទប់សិក្សាទំនើប និងបានបំពាក់សម្ភារៈបរិក្ខាពេញលេញ និងប្រើប្រាស់វិធីសាស្ត្របង្រៀនបែបសតវត្សទី២១ ដោយមានសិស្ស១៥នាក់ឬតិចជាងនេះក្នុងមួយថ្នាក់។🡻

*🡹 សម្ភារៈបរិក្ខាអប់រំទំនើបនៅមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី ដោយរចនាឡើងឱ្យមានខ្យល់ចេញចូល និងថ្នាក់រៀនមានពណ៌ចម្រុះ។*



# រូបភាពសកម្មភាព



**← កម្មវិធីអនុវត្តថ្មីរបស់សាលារៀនជំនាន់ថ្មី៖** *កុមារនៅសាលាអនុវត្ត ហ៊ុន សែន កំពង់ចាមធ្វើកម្មវិធីសមាធិមុនពេលចាប់រៀនដោយយកលំនាំតាមកម្មវិធីទស្សនកិច្ចសិក្សាពីប្រទេសថៃ ហើយបច្ចុប្បន្ននេះ លោកគ្រូអ្នកគ្រូបានអនុវត្តនៅកម្ពុជា។*

## លក្ខណៈកម្មវិធី សាលារៀនជំនាន់ថ្មី....

### សេវាផ្តល់សិទ្ធិអំណាចយុវជន

គោលការណ៍ផ្តល់សិទ្ធិអំណាចយុវជនដែលដាក់ចេញដោយ *គោលនយោបាយអភិវឌ្ឍន៍យុវជនជាតិ របស់ក្រសួងអប់រំ យុវជន និងកីឡា* បានដើរតួនាទីសំខាន់ក្នុងគំរូសាលារៀនជំនាន់ថ្មី។ គោលការណ៍ផ្តល់សិទ្ធិអំណាចយុវជនបានផ្តល់ជម្រើសដល់សិស្សក្នុងការជ្រើសរើសប្រភេទមុខវិជ្ជា ដែលពួកគាត់ចង់សិក្សា និងស្ម័គ្រចិត្តក្នុងក្លឹបសិក្សា។ សេវាប្រឹក្សាអាជីពបានផ្តល់ឱ្យយុវជនជួយធានាថាការសម្រេចចិត្តរបស់ពួកគាត់បានត្រឹមត្រូវ។

### សេវាសិស្សពិសេស

សាលារៀនជំនាន់ថ្មីផ្តល់សេវាកម្មឱ្យសិស្សថ្មីដែលមិនមាននៅក្នុងសាលារៀនសាធារណៈធម្មតា រួមមាន៖ បណ្ណាល័យអេឡិត្រនិចសតវត្សរ៍ទី២១ សេវាប្រឹក្សាអាជីព ក្លឹបសិក្សាតាមមុខវិជ្ជា កម្មវិធីបំណិនជីវិត ការវាយតម្លៃតាមអេឡិចត្រូនិច និងការសិក្សាតាមសុសវែរ។



**←តម្រូវការដ៏ច្រើនលើស លប់សម្រាប់ការចូលរៀននៅNGS៖** *ឪពុកម្តាយសិស្សពេញសាលប្រជុំនៅវិទ្យាល័យព្រះស៊ីសុវត្ថិច្រើនហូរហៀដោយសង្ឃឹមថាកូនគាត់បានចូលរៀននៅសា លានេះ។ សិស្សជាង១.២០០នាក់បានដាក់ពាក្យចូលរៀនដោយសាលាមានតែ ២០០កៅអីប៉ុណ្ណោះនៅឆ្នាំសិក្សា២០១៩ នេះ។*





**←ការបង្កើតបណ្ណាល័យសតវត្សរ៍ទី២១៖** *កម្មវិធី NGS បញ្ចប់ការកែលម្អបណ្ណាល័យទំនើបមួយនៅវិទ្យាល័យ ហ៊ុន សែន ពាមជីកង។*

**សាលប្រជុំសតវត្សរ៍ទី២១ សម្រាប់សាលារៀនសតវត្សរ៍ទី២១៖** *សិស្សនៅវិទ្យាល័យ ហ៊ុន សែន កំពង់ចាម រីករាយនឹងសាលប្រជុំថ្មីរបស់ពួកគេដោយមានការរចនាទំនើប។ សាលប្រជុំបានបំពាក់សម្ភារបរិក្ខាពេញលេញ ឧបករណ៍បំពងសំឡេង និងបន្ទប់វង់ចាំដ៏ស្រស់ស្អាត (ខាងលើ)។ ទិដ្ឋភាពនៅខាងក្រៅសាលប្រជុំថ្មីនៅវិទ្យាល័យ ហ៊ុន សែន កំពង់ចាម បានផ្តល់នៅភាពផ្ទុយគ្នាស្រឡះទៅនឹងស្ថាបត្យកម្មបែបបូរាណដែលបានប្រើប្រាស់នៅសាលារៀនសាធារណៈ(ខាងស្តាំ)។* ↑





**↑ ការលើកកម្ពស់ការស្រាវជ្រាវរបស់សិស្ស៖** *សិស្សនៅវិទ្យាល័យព្រែកលៀបប្រើប្រាស់កុំព្យូទ័រនៅក្នុងបណ្ណាល័យថ្មីរបស់គេដើម្បីស្រាវជ្រាវមេរៀនសម្រាប់ការងារគម្រោងពិសេស។ ការស្រាវជ្រាវរបស់សិស្សម្នាក់ៗគឺជាកត្តាសំខាន់នៃកម្មវិធីអប់រំនៅសាលារៀនជំនាន់ថ្មី។*




**ការបង្កើតឯកសារណែនាំបណ្ណាល័យសតវត្សរ៍ទី២១ថ្មី៖** *គម្រោងបានបង្កើតឯកសារណែនាំស្តង់ដាមួយដើម្បីជួយគម្រោងផ្សេងៗទៀតយកលំនាំអនុវត្តតាមការរៀបចំបែបទំនើប និងការគ្រប់គ្រងដែលបានប្រើប្រាស់ក្នុងបណ្ណាល័យកម្មវិធីសាលារៀនជំនាន់ថ្មី។*



**↑ ការធ្វើឱ្យប្រទេសកម្ពុជាមានមោទនភាព៖** *សិស្សមកពីវិទ្យាល័យព្រះស៊ីសុវត្ថិបានបង្ហាញមេដាយខ្លះដែលពួកគាត់ឈ្នះនៅការប្រកួតថ្នាក់អន្តរជាតិនៅក្នុងឆ្នាំសិក្សានេះ។ សាលារៀនជំនាន់ថ្មីផ្តល់ការតស៊ូមតិដ៏អស្ចារ្យសម្រាប់សិស្សដែលអាចចូលរួមការប្រកួតថ្នាក់ជាតិ និងអន្តរជាតិជាច្រើនដែលបានលើកទឹកចិត្តដល់ការសិក្សារបស់សិស្ស។*

# គម្រោង សាលារៀនជំនាន់ថ្មី (NGS) - ស្វាយរៀង

*" ជាសាលាជម្នុញានឹបូងនៅក្នុងប្រទេសកម្ពុជា "*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការឆាលហ្វាន កម្ពុជា |
| អ្នកទទួលផលផ្ទាល់ | សិស្សសរុប ៧៥៧នាក់ |
| ថវិកាទទួលបានក្នុងឆ្នាំ២០១៩ | ១៤៦,៥២៦ ដុល្លារអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផល | ១៩៤ ដុល្លារអាមេរិក |
| ខេត្តគ្របដណ្ដប់ | ស្វាយរៀង |
| ចំនួនស្រុកគ្របដណ្ដប់ | ស្វាយជ្រំ |
| មធ្យមសិក្សាគោលដៅ | ១ |
| បឋមសិក្សាគោលដៅ | ១ |
| កាលបរិច្ឆេទចាប់ផ្ដើមគម្រោង | កក្កដា ២០១៨ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | សីហា ២០២១ |

## សកម្មភាពសំខាន់ៗ

**កម្មវិធីវគ្គថ្មី៖** អង្គការ ខេប បានវិនិយោគនៅអនុវិទ្យាល័យគោកព្រីង និងបឋមស្វាយព្រហូតរយៈពេល៣ឆ្នាំក្នុងវគ្គទី១ក្នុងឆ្នាំ២០១៧។ វគ្គថ្មីនេះ យើងបានទទួលមូលនិធិពីអង្គការឆាលហ្វានកម្ពុជាក្នុងឆ្នាំ២០១៨ ដែលយកចិត្តទុកដាក់លើការវាយតម្លៃទទួលស្គាល់សម្រាប់អនុវិទ្យាល័យគោកព្រីង។

**ការទទួលស្គាល់ជាសាលារៀនជំនាន់ថ្មី៖** ការទទួលស្គាល់ជាសាលារៀនជំនាន់ថ្មីនៃអនុវិទ្យាល័យគោកព្រីង ត្រូវបានទទួលស្គាល់ក្នុងឆ្នាំ២០១៩ ហើយវិញ្ញាបនបត្រត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំយុវជននិងកីឡា។ ការទទួលស្គាល់នេះជាជំហានដ៏រឹងមាំមួយសម្រាប់កម្មវិធី និងការបើកផ្លូវដើម្បីទទួលមូនិធិពីរដ្ឋាភិបាល ដូចដែលមានចែងក្នុងគោលការណ៍ណែនាំប្រតិបត្តិសាលារៀនជំនាន់ថ្មី ដែលស្នើរឱ្យមានការគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា ចំពោះការទទួលស្គាល់សាលារៀនដទៃទៀតដោយក្រុមប្រឹក្សាភិបាលថ្នាក់ជាតិ។ ដូច្នេះ អង្គការ ខេប និងអង្គការឆាលហ្វានកម្ពុជានឹងកាត់បន្ថយការគាំទ្រផ្ដល់ឱ្យរាជរដ្ឋាភិបាលនឹងសហគមន៍គាំទ្របន្តនាពេលអនាគត។

**អនុវិទ្យាល័យគោលព្រីងបានប្រែក្លាយជាវិទ្យាល័យគោកព្រីង៖** ស្តង់ដាខ្ពស់អនុវិទ្យាល័យគោកព្រីង ចំពោះការអភិវឌ្ឍសាលារៀនដែលមានចំណាប់អារម្មណ៍ពីថ្នាក់ដឹកនាំបានសម្របសម្រួលឱ្យសាលាមួយនេះប្រែក្លាយទៅជាវិទ្យាល័យ។ លក្ខខណ្ឌនេះបានឯកភាពគ្នារវាងថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡា និងក្រសួងអប់រំ យុវជន និងកីឡាខេត្ត ដើម្បីឱ្យមានការប្រែក្លាយទៅជាវិទ្យាល័យចាប់ពីឆ្នាំសិក្សា ២០១៩-២០២០។ មន្ទីរអប់រំ យុវជន និងកីឡាបានផ្ដល់មូនិធិសាងសង់អគារសិក្សាមួយខ្នង ៥បន្ទប់ ដើម្បីបំពេញតម្រូវការ។

**ផែនការស្នូលអភិវឌ្ឍន៍បឋមស្វាយព្រហូត៖** ក្រោយពេលបញ្ចប់ការអភិវឌ្ឍវគ្គទី១ក្នុងឆ្នាំ២០១៧ មានអនុសាសន៍មួយចំនួនពីក្រុមកាងារវាយតម្លៃឯករាជ្យ ត្រូវបានផ្អាកការវិនិយោគសម្រាប់បឋមសិក្សាស្វាយព្រហូត ដែលនៅក្នុងបរិវេណជាមួយអនុវិទ្យាល័យគោកព្រីងដែលបានការទទួលស្គាល់ពីក្រសួង។ បច្ចុប្បន្នការទទួលស្គាល់នេះ អង្គការឆាលហ្វាន និងអង្គការ ខេប បានសម្រេចចិត្តសារជាថ្មីដើម្បីផ្ដល់វិនិយោគសម្រាប់អភិវឌ្ឍសាលាបឋមសិក្សាស្វាយព្រហូតឡើងវិញ។

**ការទស្សនកិច្ចតំណាងរាស្ត្រ៖** ប្រធានគណៈកម្មាធិការទី៧នៃរដ្ឋសភា ឯកឧត្តម ហ៊ុន ម៉ានី បានមកទស្សកិច្ចអនុវិទ្យាល័យគោកព្រីងនៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៩ ដើម្បីកែប្រែអនុវិទ្យាល័យឱ្យមានការប្តូរមុខមាត់ថ្មី។

## សន្និធានភាពនៃកម្មវិធី

កម្មវិធីសាលារៀនជំនាន់ថ្មីក្នុងខេត្តស្វាយរៀង ក៏ដូចគ្នាទៅនឹងកម្មវិធីសាលារៀនជំនាន់ថ្មីថ្នាក់ជាតិដទៃទៀតដែលផ្ដល់ជំនួយផ្ទាល់ដោយក្រសួងអប់រំយុវជននិងកីឡា និងប្រតិបត្តិដោយអង្គការ ខេប។ លក្ខណៈពិសេសកម្មវិធីសាលារៀនជំនាន់ថ្មីខេត្តស្វាយរៀង រួមមានទាំងការបង្កើតសាលារៀនស្វ័យតសាធារណៈក្នុងការវិនិយោគ ដើម្បីទទួលបានការអប់រំជាស្តង់ដាកម្រិតខ្ពស់។ បទដ្ឋានទាំងនេះគឺសញ្ញាណឱ្យមានការទទួលស្គាល់ស្របតាមបទដ្ឋាន ដែលបានកំណត់នៅក្នុងក្របខ័ណ្ឌគោលនយោបាយដែលបានសម្រេច។ដូច្នេះ អភិបាលកិច្ច គណនេយ្យភាព និងកម្រិតវិជ្ជាជីវៈខ្ពស់គឺជាធាតុសំខាន់របស់កម្មវិធី។ ការសាកល្បងសាលារៀនជំនាន់ថ្មីនៅក្នុងខេត្តស្វាយរៀងគឺជាផ្នែកមួយដែលខុសពីកម្មវិធីថ្នាក់ជាតិ ការទាក់ទងការជ្រើសរើសសាលានៅក្នុងតំបន់ជនបទដាច់ស្រាយាល។ បច្ចុប្បន្ននេះ គឺប្រាកដថា មានសាលាគំរូមួយនៅក្នុងជនបទ ដោយមានកាទទួលស្គាល់ពីក្រុមប្រឹក្សាភិបាលថ្នាក់ជាតិ ជាសាលារៀនជំនាន់ថ្មីក្នុងឆ្នាំនេះ។ ដូច្នេះក្តី ការសាកល្បងនេះប្រើរយៈពេលអស់៣ឆ្នាំលើការវិនិយោគដើម្បីឆ្លើយតបទៅនឹងស្តង់ដាតាមគោលនយោបាយរបស់ក្រសួង និងរក្សាជំហារនេះសម្រាប់អនាគតកាល។

## រូបភាពសកម្មភាព


ចំណូលបានមកពីសួនជីវៈនៅសាលារៀនជំនាន់ថ្មី ខេត្តស្វាយរៀង។


ការពិព័រណ៍ស្នាដៃរបស់សិស្សសាលារៀនជំនាន់ថ្មី


ទស្សនកិច្ចនៅសាលារៀនជំនាន់ថ្មីព្រៃកលៀប


សកម្មភាពបន្ទប់កុំព្យូទ័រ (ICT Lap)


☜ ទិវាគ្រូបង្រៀនត្រូវបានរៀបចំឡើងចែករំលែកសេចក្ដីដឹងគុណដល់គ្រូបង្រៀនសម្រាប់ការខិតខំប្រឹងប្រែងនៅក្នុងការបង្រៀន។

ទិវាប្រកួតអំណានរៀបចំធ្វើនៅវិទ្យាល័យគោកព្រីងដើម្បីឆ្លុះបញ្ចាំងអំពីសមត្ថភាពអានកម្រិតខ្ពស់របស់សិស្សបានមកពីលទ្ធផលវិនិយោគក្នុងពេលថ្មីៗនេះ។ បច្ចុប្បន្ននេះ មានទិវាប្រចាំឆ្នាំសម្រាប់សិស្សនឹងអនុវត្តរៀងរាល់ឆ្នាំ។ ☞



## ការតាំងពិព័រណ៍ រាត្រីជួបជុំឪពុកម្តាយ

ជារៀងរាល់ឆ្នាំ សាលារៀនជំនាន់ថ្មីរៀបចំការតាំងពិព័រណ៍ស្នាដៃសិស្សដើម្បីបង្ហាញឪពុកម្តាយនូវអ្វីដែលពួកគេបានសិក្សា។ ហេតុផលតាំងពិព័រណ៍នេះជាការបង្ហាញចំណេះដឹងដល់ឪពុកម្តាយ។ ការតាំងពិព័រណ៍នេះរៀបចំឡើងនាពេលរសៀល និងពេលល្ងាចមិនប៉ះពាល់ដល់ម៉ោងការងារដែលអាចឱ្យឪពុកម្តាយអាចមកទស្សនាសមិទ្ធផលនានាក្នុងវិទ្យាល័យគោកព្រីង។ វិទ្យាល័យគោកព្រីងមានអំណោយសាលារៀនខ្លះៗសម្រាប់ចំណាយលើសម្ភារៈ និងការបង្កើតស្នាដៃសិស្សតាមក្លឹបនីមួយៗ។ ឆ្នាំនេះសិស្សានុសិស្សបានបង្កើតស្នាដៃតាមក្លឹបបានចំនួន ៥២ស្តង់ រាប់បញ្ចូលទាំងការតបណ្តាញចរន្តអគ្គិសនីប្រើប្រាស់តាមផ្ទះ។



**រាត្រីជួបឪពុកម្តាយ:** សិស្សបង្កើតគម្រោងដ៏ច្រើនអស្ចារ្យ ព្រមទាំងបង្កើតម៉ាស៊ីនភ្លើងសម្រាប់ផលិតអគ្គិសនី។

## លក្ខណៈកម្មវិធី


ការសិក្សាវិទ្យាសាស្ត្រដោយធ្វើពិសោធន៍ផ្ទាល់ក្នុងបន្ទប់រៀន។

## សាលារៀនសម្រាប់ជំនាន់ថ្មី...
### ការជ្រើសរើសគ្រូបង្រៀនសាលារៀនជំនាន់ថ្មី ជាមូលដ្ឋាននាអនាគត

ស្តង់ដាបង្រៀនមានការរីកចម្រើនជាបន្តបន្ទាប់ក្នុងឆ្នាំនេះ ដោយមានការជ្រើសរើសគ្រូថ្មីចំនួន ៧នាក់បន្ថែមសម្រាប់បម្រើការងារក្នុងវិទ្យាល័យគោកព្រីង។ ក្នុងចំណោមគ្រូ ២៨នាក់ ដែលបានជ្រើសរើសឱ្យបម្រើការងារក្នុងសាលានេះ ៨៨% ទទួលបានបរិញ្ញាបត្រ និង ២៥% បន្តសិក្សានៅវិទ្យាស្ថានជាតិអប់រំសម្រាប់បង្រៀនកម្រិតថ្នាក់ទី១០ ទើបបង្កើតថ្មី។ លោកគ្រូអ្នកគ្រូចេះប្រើប្រាស់បច្ចេកវិទ្យាកម្រិតខ្ពស់ ហើយមានសមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានបម្រើឱ្យការបង្រៀននិងរៀននៅក្នុងសាលារៀនជំនាន់ថ្មី។ គ្រូដែលបានជ្រើសរើសឱ្យមកបម្រើការងារនៅក្នុងសាលាមួយនេះ ភាគច្រើនពួកគាត់វ័យក្មេង និងមានឆន្ទៈខ្ពស់។ វប្បធម៌សហគមន៍ចែករំលែកគឺមានភាពស្វាហាប់ និងផ្តល់ចំណេះដឹងបទពិសោធន៍ពីគ្នាទៅវិញទៅមក បង្កើនសមត្ថភាពបង្រៀននិងរៀនរបស់ពួកគាត់។ ពួកគាត់មានការពិភាក្សាគ្នាយ៉ាងសកម្មស្តីពីវិធីសាស្ត្របង្រៀន ដូចជា ការសិក្សាបែបស្ថាបនានិយមស្របតាមកម្មវិធីសិក្សារដ្ឋ។



ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានធ្វើទស្សនកិច្ចនៅសាលារៀនជំនាន់ថ្មីគោកព្រីងដែលជាបេសកកម្មស្វែងរកការពិត។


ការធ្វើទម្រង់តេស្តសិស្សបឋមសិក្សាថ្នាក់ទី៣


ទស្សនកិច្ចឯកអគ្គរដ្ឋទូតចក្រភពអង់គ្លេស


កិច្ចប្រជុំស្តីពី PLC បង្ហាញពីសមត្ថភាពគ្រូ ICT កម្រិតខ្ពស់

# គម្រោង សៀវភៅសម្រាប់កម្ពុជា (BFC)

*"បង្កើនការលូតលាស់ជីវិតកុមារតាមរយៈសៀវភៅសិក្សា និងប្រព័ន្ធផ្សព្វផ្សាយ"*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| **ម្ចាស់ជំនួយ** | អង្គការមូលនិធិអាស៊ី និងក្រសួងអយក |
| **អ្នកទទួលផលផ្ទាល់** | ១១៨.២៥៦នាក់(ស្រី ៦១.៣៧៤នាក់) |
| **ថវិកាបដិភាគទទួលបានឆ្នាំ២០១៩** | ៣៦៤.០៣៨,៩៦ ដុល្លារអាមេរិក |
| **ថវិកាសម្រាប់អ្នកទទួលផល** | ៣,០៨ ដុល្លារអាមេរិក |
| **ខេត្តគ្របដណ្តប់** | ៩ (រាប់ទាំងរាជធានីភ្នំពេញ) |
| **ចំនួនស្រុកគ្របដណ្តប់** | ៣៩ |
| **វិទ្យាស្ថានរដ្ឋាភិបាល និងសាកលវិទ្យាល័យគោលដៅ** | ៦ |
| **អង្គការមិនមែនរដ្ឋាភិបាលគោលដៅ** | ១ |
| **អនុវិទ្យាល័យគោលដៅ** | ១២៤ |
| **បឋមសិក្សាគោលដៅ** | ២ |
| **វិទ្យាស្ថានដទៃទៀត** | 0 |
| **កាលបរិច្ឆេទចាប់ផ្តើមគម្រោង** | ០១ មេសា ២០១៤ |
| **កាលបរិច្ឆេទបញ្ចប់គម្រោង** | ៣១ ធ្នូ ២០២២ |

## បច្ចុប្បន្នភាពគម្រោង

កម្មវិធីសៀវភៅសម្រាប់កម្ពុជាបានបញ្ចប់កិច្ចប្រតិបត្តិការរយៈពេល៦ឆ្នាំ ហើយបច្ចុប្បន្ននេះកម្មវិធីបានបន្តរៀបចំដំណើរការចែកចាយសៀវភៅទៅខេត្តចំនួន ៥ ក្នុងឆ្នាំ២០២០នេះ មានដូចជា៖ ខេត្តព្រះសីហនុ កោះកុង កំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង។ អនុស្សរណៈយោគយល់គ្នាថ្មីជាមួយក្រសួងអប់រំ យុវជន និងកីឡា អង្គការមូលនិធិអាស៊ីបានកំណត់ដំណាក់កាលពង្រីកការបរិច្ចាគសៀវភៅ ដែលនឹងទទួលបានអត្ថប្រយោជន៍ដល់រាជធានី ខេត្តក្រុងទាំង ២៥ នៅក្នុងប្រទេសកម្ពុជា។ អនុវិទ្យាល័យ និងវិទ្យាល័យជាង ២០០ ក្នុងខេត្តគោលដៅថ្មីនឹងមានសិទ្ធិដាក់ពាក្យសុំអំណោយសៀវភៅពីកម្មវិធីនាឆ្នាំក្រោយ។ កម្មវិធី BfC ក៏កំពុងរៀបចំកំណត់អត្តសញ្ញាណសាលា ដែលមានសក្តានុពលដើម្បីធ្វើជាបណ្ណាល័យពិសោធន៍ (លើបណ្តាញអ៊ីនធើណិត) ដែលនឹងត្រូវបង្កើតឡើងនៅក្នុងឆ្នាំ២០២០។

## ផលជះរបស់គម្រោង

**ការបង្កើតបាននូវវប្បធម៌រៀន:** BfC បន្តផ្តល់ជំនួយបច្ចេកទេសដល់បណ្ណារក្សនៅទូទាំងប្រទេសដើម្បីជួយសម្រួលដល់ការចូលប្រើសៀវភៅរបស់សិស្ស ដែលត្រូវនឹងចំណាប់អារម្មណ៍របស់ពួកគាត់។ បណ្ណារក្សត្រូវបានបណ្តុះបណ្តាលឱ្យចេះរៀបចំក្រុមអានសម្រាប់កុមារតូចៗនៅក្នុងសាលាពួកគាត់ និងដើម្បីជួយសម្រួលដល់ការចូលប្រើសៀវភៅអេឡិចត្រូនិកដោយប្រើឧបករណ៍សិក្សាចល័តដែលបានផ្គត់ផ្គង់ដល់បណ្ណាល័យដោយកម្មវិធីផ្សេងទៀតរបស់អង្គការ ខេប។

**ការលើកកម្ពស់បណ្ណាល័យ:** BfC បានផ្តល់សៀវភៅអានជាច្រើនដល់បណ្ណាល័យសាលារៀនទូទាំងប្រទេស។ ចាប់តាំងពីបានបង្កើតកម្មវិធីនេះឡើង BFC បានចែកចាយសៀវភៅ និងសម្ភារៈអានចំនួន ៥៩.១២៩ ទៅសាលារៀន និងបណ្ណាល័យសាធារណៈចំនួន ៣៩៧ កន្លែងនៅទូទាំងប្រទេសកម្ពុជា។

**ការសម្លឹងមើលទៅថ្ងៃអនាគត:** នៅក្នុងអំឡុងឆ្នាំ ២០១៩ BFC បានធ្វើការចែកចាយដល់ខេត្តចំនួន១១។ នៅឆ្នាំក្រោយ BfC នឹងបន្ថែមខេត្តថ្មីចំនួន ៥ ទៅក្នុងគោលដៅចែកចាយរបស់ខ្លួន។ លើសពីនេះកម្មវិធីនឹងបន្តរៀបចំការប្រកួតប្រកបពាក្យនៅតាមសាលារៀនបន្ថែមទៀត។ ក្នុងឆ្នាំសិក្សា២០១៩ BFC បានរៀបចំព្រឹត្តិការណ៍ប្រកួតការប្រកបពាក្យចំនួន ១៥ ព្រឹត្តិការណ៍ហើយនឹងព្យាយាមបង្កើនចំនួននេះនាពេលអនាគត។ ព្រឹត្តិការប្រកួតការប្រកបពាក្យបានជួយជំរុញការរៀន និងអានអង់គ្លេសរបស់សិស្ស។ អនុស្សរណៈយោគយល់ថ្មីៗដែលបានចុះហត្ថលេខាជាមួយក្រសួង និងអង្គការមូលនិធិអាស៊ី ផ្តល់អាទិភាពដល់អនុវិទ្យាល័យ និងកំណត់ទិសដៅខេត្តថ្មីចំនួន ៥ រាល់ឆ្នាំ មានគោលបំណងគ្របដណ្តប់ខេត្តទាំង២៥ក្នុងរយៈពេល៥ឆ្នាំ។

**លើកកម្ពស់ការតាមដាន:** BfC នឹងពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការប្រើប្រាស់សៀវភៅអង់គ្លេសឱ្យបានច្រើនបំផុតដោយការត្រួតពិនិត្យសាលារៀនឱ្យបានញឹកញាប់ជាងមុន។ បច្ចុប្បន្ននេះ BfC បានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដូចជា Telegram និង Facebook ដើម្បីចែករំលែក និងតាមដានសកម្មភាពអាន។ BfC នឹងធ្វើការស្ទង់មតិអំពីការប្រើប្រាស់សៀវភៅដោយប្រើពេលវេលាជាក់ស្តែងជាមួយប្រព័ន្ធ KoBo និង Google Survey។

## គោលបំណង

អនុស្សរណៈយោគយល់ថ្មីរបស់កម្មវិធីជាមួយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការមូលនិធិអាស៊ីបានផ្តល់អាទិភាពដល់ការបរិច្ចាគសៀវភៅដល់សាលាមធ្យមសិក្សាដោយផ្តោតលើខេត្តថ្មីចំនួន ៥ ជារៀងរាល់ឆ្នាំដោយមានគោលបំណងគ្របដណ្តប់ទាំង២៥ខេត្តក្រុងក្នុងរយៈពេល ៥ឆ្នាំ។ គម្រោងព្យាយាមលើកកម្ពស់ការអានភាសាអង់គ្លេសនៅកម្រិតអនុវិទ្យាល័យនិងវិទ្យាល័យ។ នៅឆ្នាំសិក្សាបន្ទាប់ BfC នឹងជ្រើសរើសយកសាលាដែលលេចធ្លោមួយក្នុងចំណោមសាលារៀនចំនួន ២០០ ដើម្បីសាកល្បងឱ្យដំណើរការបណ្ណាល័យសាធារណៈ។

## សកម្មភាពសំខាន់ៗ

- BFC បានបន្តដំណើរការស្នើសុំសៀវភៅពីសាលារៀន និងបានចែកចាយសៀវភៅភាសាអង់គ្លេសចំនួន ២២.៤៥៦ក្បាលក្នុងឆ្នាំ២០១៩។ សៀវភៅទាំងនេះគឺជាការបោះពុម្ពដែលមានគុណភាពខ្ពស់បានផ្តល់ដោយក្រុមហ៊ុនបោះពុម្ពផ្សាយនៅសហរដ្ឋអាមេរិក។
- អង្គការ ខេប បានធ្វើការត្រួតពិនិត្យ និងវាយតម្លៃលើការប្រើប្រាស់សៀវភៅជាប្រចាំដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដូចជា តេឡេក្រាម និងហ្វេសប៊ុក។
- អ្នករៀបចំផែនការកម្មវិធីបានចងក្រងរបាយការណ៍លទ្ធផលវាយតម្លៃជាមួយនឹងអនុសាសន៍ជាក់ស្តែងក្នុងការគ្រប់គ្រងដើម្បីទទួលបានសៀវភៅជាអតិបរមា។
- BfC បានធ្វើការស្ទង់មតិជាក់ស្តែងនៅតាមសាលារៀនដោយប្រើ KoBoToolBox និង Google Survey ដើម្បីតាមដានការចូលប្រើសៀវភៅដែលបរិច្ចាគ។
- បុគ្គលិកគម្រោងបានលើកទឹកចិត្តសកម្មភាពអានតាមរយៈការរៀបចំឱ្យមានព្រឹត្តិការណ៍ប្រកួតប្រកបពាក្យ និងការផ្សព្វផ្សាយដល់ឪពុកម្តាយដើម្បីគាំទ្រសកម្មភាពអាននៅផ្ទះ។

## រូបភាពសកម្មភាព



*នាយកអង្គការ ខេប (ស្តាំ) និងនាយកអង្គការមូលនិធិអាស៊ី (ឆ្វេង) ចុះហត្ថលេខាលើអនុសារណៈយោគយល់គ្នាជាមួយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបន្តពង្រីកកម្មវិធី BfC ។*



***កម្មវិធីប្រកួតប្រកបពាក្យភាសាអង់គ្លេស៖*** *កូនសិស្សខាងលើកំពុងតែប្រកួតប្រជែងការប្រកបពាក្យក្នុងចំណោមបេក្ខជនជាច្រើនទៀតដែលបានរៀបចំដោយ BFC ។ ព្រឹត្តិការណ៍នេះជួយលើកទឹកចិត្តសិស្សានុសិស្សឱ្យស្រឡាញ់ការអានសៀវភៅភាសាអង់គ្លេស និងជួយអភិវឌ្ឍន៍ជំនាញប្រកបពាក្យពួកគាត់បានប្រសើរឡើង ។*

# គម្រោង ស្បៀងអាហារសម្រាប់ការអប់រំ (FFE)

*“ការលើកកម្ពស់បរិស្ថានសិក្សាដើម្បីការលូតលាស់កុមារ ”*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| **ម្ចាស់ជំនួយ** | ក្រសួងកសិកម្មសហរដ្ឋអាមេរិក ( USDA)<br>អង្គការស្បៀងអាហារពិភពលោក<br>អង្គការអប់រំពិភពលោក |
| **អ្នកទទួលផលផ្ទាល់** | គ្រូបង្រៀនថ្នាក់ទី១-៣ នៅក្នុង ៥០៣ សាលា |
| **ថវិកាបដិភាគទទួលបានឆ្នាំ២០១៩** | ១២៩.៩៨៤ ដុល្លាអាមេរិក |
| **ថវិកាសម្រាប់អ្នកទទួលផលម្នាក់** | គ្មាន |
| **ខេត្តគ្របដណ្ដប់** | ២ ខេត្ត ( កំពង់ធំ និងសៀមរាប ) |
| **ចំនួនស្រុកគ្របដណ្ដប់** | ១៨ ស្រុក ( ៧ កំពង់ធំ ១១ សៀមរាប ) |
| **បឋមសិក្សាគោលដៅ** | ៥០៣ សាលា ( ២០៥ សាលាក្នុងខេត្តកំពង់ធំ និង ២៩៨ សាលាក្នុងខេត្តសៀមរាប ) |
| **កាលបរិច្ឆេទចាប់ផ្ដើមគម្រោង** | ០១ វិច្ឆិកា ឆ្នាំ២០១៦ |
| **កាលបរិច្ឆេទបញ្ចប់គម្រោង** | ៣១ តុលា ២០១៩ |

## បច្ចុប្បន្នភាពគម្រោង

គម្រោង FFE នឹងត្រូវបានបញ្ចប់ក្នុងឆ្នាំទី៣នេះ ជាឆ្នាំដែលត្រូវអនុវត្តចុងក្រោយនៃវដ្តគម្រោងរយៈពេល៣ឆ្នាំត្រឹមឆ្នាំ២០១៩។ គម្រោង FFE បានប្រតិបត្តិការរួមគ្នាដោយអង្គការអប់រំពិភពលោក និងអង្គការ ខេប ហើយផ្ដោតលើការពង្រឹងអំណានថ្នាក់ដំបូង ដោយបញ្ចូលក្នុងសាលាដែលអនុវត្តកម្មវិធីស្បៀងអាហារពេលព្រឹក ដែលគាំទ្រដោយក្រសួងកសិកម្មសហរដ្ឋអាមេរិក។ អង្គការ ខេប ទទួលខុសត្រូវជាចម្បងសម្រាប់ការបណ្ដុះបណ្ដាលគ្រូនិងការត្រួតពិនិត្យតាមដានសាលារៀន។ នៅក្នុងឆ្នាំចុងក្រោយប្រតិបត្តិការគម្រោង FFE បានគាំទ្រការបញ្ចូលបច្ចេកទេសដល់សាលាបឋមសិក្សាគោលដៅចំនួន ៥០៣សាលា។ ការបណ្ដុះបណ្ដាលគ្រូ និងការត្រួតពិនិត្យញឹកញាប់គឺជាធាតុសំខាន់របស់កម្មវិធីគម្រោង FFE។ គម្រោងបានព្យាយាមតម្រឹមសកម្មភាពបណ្ដុះបណ្ដាលគ្រូឱ្យត្រូវជាមួយនឹងផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ( TPAP )។ ក្រេឌីត និងវិញ្ញាបនបត្រនឹងត្រូវផ្ដល់ឱ្យគ្រូនៅពេលបញ្ចប់វគ្គបណ្ដុះបណ្ដាល និងរៀបចំធ្វើតេស្តអំណានថ្នាក់ដំបូង ( EGRA ) ដែលបានរៀបចំដោយនាយកដ្ឋានបឋមសិក្សា។ តាំងពីចាប់ផ្ដើមក្រុមការងារគម្រោងបានបង្កើតសៀវភៅបណ្ដុះបណ្ដាល៥ម៉ូឌុលស្ដីពីការបង្រៀនអំណាន ហើយបានយកទៅបណ្ដុះបណ្ដាលគ្រូចំនួន ២.៥៧៥នាក់នៅថ្នាក់ទី១-៣។ក្រុមការងារក៏បានផ្ដល់ការបណ្ដុះបណ្ដាលដូចគ្នានេះដល់នាយកសាលាចំនួន ៧១៤នាក់ ក្នុងចំណោមសាលាទាំងអស់ក្នុងគម្រោង ដូច្នេះ ពួកគាត់អាចផ្ដល់នូវលក្ខខណ្ឌអភិបាលកិច្ចល្អ ដើម្បីជួយគាំទ្រវិធីសាស្ត្រគរុកោសល្យថ្មីនេះ។ ការវាយតម្លៃអំណានថ្នាក់ដំបូងចុងក្រោយត្រូវបានធ្វើតេស្តលើសិស្សថ្នាក់ទី២ នៅក្នុងសាលារៀនចំនួន ៧០សាលា ( សិស្ស ១.៤០០ នាក់ )។ ការធ្វើតេស្តនេះជាទម្រង់សម្រាប់វាស់ការប្រៀបធៀបជាមួយនឹងការធ្វើតេស្តពាក់កណ្ដាលគម្រោងដែលធ្វើកាលពីឆ្នាំមុន។

នៅពេលគម្រោងបានបញ្ចប់ អង្គការ ខេប បានជួយដល់អង្គការអប់រំពិភពលោកក្នុងការធ្វើតេស្ត EGRA កំណត់ពីផលជះនៃកម្មវិធី និងសង្កេតការបង្រៀនគ្រូចំនួន ៣៦៨នាក់ក្នុងឆ្នាំសិក្សា២០១៩។ តាមសំណើអង្គការអប់រំពិភពលោក អង្គការ ខេប គួរជួយចែកចាយកញ្ចប់កម្មវិធីសិក្សាថ្មីបង្កើតដោយទីភ្នាក់ងារ USAID ទោះបីជា អង្គការ ខេប មិនបានចូលរួមធ្វើដោយផ្ទាល់ជាមួយកម្មវិធីអានដែលឧបត្ថម្ភថវិកាដោយទីភ្នាក់ងារ USAID ក៏ដោយ វិធីសាស្ត្រដើម្បីពង្រឹងអំណាននេះពិតជាខុសៗគ្នា។ សេចក្ដីសន្និដ្ឋាន ការចូលរួមអង្គការខេបនៅក្នុងគម្រោង FFE នឹងត្រូវផ្អាកក្នុងភាពជាដៃគូអប់រំយូរអង្វែងរបស់អង្គការអប់រំពិភពលោក និងអង្គការ ខេប ដែលជាដៃគូធ្វើការតាំងពីឆ្នាំ២០០៣ បណ្ដោះអាសន្នសិន។ ទោះបីជាយ៉ាងណា អង្គការ ខេប សង្ឃឹមថានឹងមានឱកាសនាពេលអនាគតសម្រាប់ពួកយើងដើម្បីធ្វើការរួមគ្នាម្ដងទៀតជាមួយអង្គការអប់រំពិភពលោក។

## សកម្មភាពសំខាន់ៗ

១. ការបណ្ដុះបណ្ដាលនាយកសាលា
២. ការធ្វើតេស្តវាយតម្លៃអំណានថ្នាក់ដំបូង ( ថ្នាក់ទី២ ) តាមដានការរីកចម្រើនអំណាន
៣. ការអភិវឌ្ឍសៀវភៅបណ្ដុះបណ្ដាលគ្រូ និងការរៀបចំសិក្ខាសាលានៅទូទាំង ៥០៣ សាលាបឋមសិក្សា
៤. ការខិតខំលើកកម្ពស់អំណានថ្នាក់ដំបូងតាមរយៈការចែករំលែកសម្ភារសិក្សា និងល្បែងអំណាន។

## គោលបំណង

គម្រោង FFE គឺដើម្បីបង្កើនលទ្ធផលសិក្សាលើអំណានភាសាខ្មែរនៅថ្នាក់ដំបូង( ថ្នាក់ទី១-៣ )។ ដើម្បីសម្រេចគោលដៅនេះ គម្រោងកំពុងធ្វើការដើម្បីបង្កើនសមត្ថភាពរបស់អ្នកគ្រប់គ្រងសាលារៀន ( នាយក និងនាយករង ) ដើម្បីលើកកម្ពស់ប្រសិទ្ធភាពអំណានថ្នាក់ដំបូងនៅសាលារៀនរបស់ពួកគាត់។ ជាពិសេសគម្រោងនេះសំដៅទៅការបង្កើតជំនាញ និងចំណេះដឹងរបស់គ្រូ និងបណ្ណារក្សក្នុងការប្រើប្រាស់វិធីសាស្ត្រគរុកោសល្យអំណានថ្នាក់ដំបូងប្រកបដោយប្រសិទ្ធភាព។ ដើម្បីពង្រឹងអំណានមានន័យថា ត្រូវប្រើប្រាស់សម្ភារសិក្សាថ្មីៗដែលបង្កើតឡើងដើម្បីពង្រឹងបំណិនអំណានកុមារឱ្យមានប្រសិទ្ធភាព។ FFE ក៏ស្វែងរកការគាំទ្រពីសាលាកម្រិតអភិវឌ្ឍន៍ផងដែរ ដើម្បីលើកកម្ពស់សកម្មភាពអំណានសម្រាប់កុមារ និងមាតាបិតា និងលើកកម្ពស់មនសិការមាតាបិតា និងសហគមន៍ក្នុងការចូលរួមលើកកម្ពស់អំណានកុមារ។

## រូបភាពសកម្មភាព

*វគ្គបណ្ដុះបណ្ដាលប្រើប្រាស់សម្ភារៈពិសេសសម្រាប់ពង្រឹងសមត្ថភាពគ្រូ។*





## ផលជះរបស់គម្រោង

អំឡុងពេល៣ឆ្នាំចុងក្រោយនេះ គម្រោងក៏បានបង្កើតនូវឯកសារបំប៉ន ៤ ម៉ូឌុលដែលផ្ដោតទៅលើអំណានថ្នាក់ដំបូងរួមមាន ៖

**ម៉ូឌុលទី ១**: ការរៀនភាសា និងដំណើរការនៃការអាន
**ម៉ូឌុលទី ២**: ការអភិវឌ្ឍអំណានអាជីព
**ម៉ូឌុលទី ៣**: ការអភិវឌ្ឍភាសា - វិធីសាស្ត្រគ្រប់គ្រង ( មានពីរវគ្គ )
**ម៉ូឌុលទី ៤**: ការវាយតម្លៃ និងការវិភាគការអនុវត្តការរៀនភាសា។

សៀវភៅទាំងនេះមានភាពងាយស្រួលប្រើ និងមានល្បែងទាក់ទាញជាច្រើនដើម្បីពង្រឹងការអនុវត្តរបស់គ្រូ។ ពួកគេបានដើរតួយ៉ាងសំខាន់ក្នុងការជួយគ្រូឱ្យបានចុះឈ្មោះចូលរួមក្នុងវគ្គគន្លងយកក្រេឌីត ក្នុងនោះគ្រូអាចទទួលបានក្រេឌីតពិសេសសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈដែលនាំឱ្យមានការប្រសើរឡើងនូវឋានៈផ្លូវការរបស់ពួកគាត់នៅក្នុងប្រព័ន្ធអប់រំ។ គន្លងយកក្រេឌីតផ្ដល់ឱកាសសម្រាប់ការងារអភិវឌ្ឍន៍ផ្ទាល់ខ្លួនជាច្រើន ដូចជា ការសិក្សាដោយខ្លួនឯង សកម្មភាពដឹកនាំ និងការវាយតម្លៃខ្លួនឯង។

បន្ទាប់ពីអន្តរាគមន៍អស់រយៈពេល ៣ឆ្នាំកន្លងមក FFE មានការអភិវឌ្ឍតិចតួចលើបំណិនអានរបស់កុមារនៅតាមសាលាគោលដៅដែលខ្លួនកំពុងធ្វើការ។មធ្យមភាគពិន្ទុតេស្ត EGRA មូលដ្ឋានបានបង្ហាញថា មានសិស្សតែ ១៦% ប៉ុណ្ណោះដែលអាចអានបានត្រឹមត្រូវ។ នៅចុងបញ្ចប់គម្រោងនេះបានកើនឡើងដល់ ៣០%។ ទោះបីជាយ៉ាងណាក៏ដោយ គម្រោងសង្ឃឹមថានឹងទទួលបានលទ្ធផលល្អប្រសើរជាងអ្វីដែលរំពឹងទុក។

# កម្មវិធីអប់រំបញ្ចូលគ្នា (IEP)

*"កម្មវិធីអប់រំបញ្ចូលគ្នា: លើកកម្ពស់សិទ្ធិអប់រំរវាងក្រុមជនជាតិ "*

ដើម្បីឱ្យប្រព័ន្ធគ្រប់គ្រង និងតាមដានការអនុវត្តកម្មវិធីនៅតាមសាលារៀនកាន់តែប្រសើរឡើង អង្គការ ខេប បានបង្កើតកម្មវិធីអប់រំបញ្ចូលគ្នាហៅកាត់ថា IEP។ គម្រោងចំនួន ៤ ស្ថិតក្រោមរចនាសម្ព័ន្ធតែមួយរបស់កម្មវិធីអប់រំបញ្ចូលគ្នា។ កម្មវិធី IEP រួមមាន៖ (១) **គម្រោងអាហារូបករណ៍និស្សិតកម្រិតឧត្តមសិក្សា(CTSP)** (២) **គម្រោង STEM4Women** (៣) **គម្រោងអាហារូបករណ៍ភាសាអង់គ្លេសខ្នាតតូច(Access)** និង (៤) **គម្រោងសកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា (KYLA)**។ កម្មវិធីអប់រំបញ្ចូលគ្នាបង្កើនការចូលរៀននៅកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា ជាពិសេសក្មេងស្រី ជនជាតិភាគតិច និងយុវជន ឬកុមារងាយរងគ្រោះ។ កម្មវិធីនេះក៏ផ្តល់ការគាំទ្រផ្នែកប្រឹក្សាអាជីព និងយុវជនមានការងារប្រកបដោយទំនុកចិត្តផងដែរ។

| | គម្រោងអាហារូបករណ៍និស្សិតកម្រិតឧត្តមសិក្ស CTSP | គម្រោងសកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា (KYLA) | គម្រោង STEM4Women | គម្រោង Access |
|---|---|---|---|---|
| **ម្ចាស់ជំនួយ** | អង្គការមូលនិធិអាស៊ី | អង្គការអ៊ិកទ្រី | អង្គការស្ត្រី 100, អង្គការ Classroom of Hope, Navitas | ស្ថានទូតអាមេរិក |
| **អ្នកទទួលផលផ្ទាល់** | សិស្សចំនួន ៣០នាក់ | សិស្សចំនួន ២.៥០០នាក់ | សិស្សចំនួន ១១នាក់ | សិស្សចំនួន ៤០នាក់ |
| **ថវិកាទទួលបានក្នុងឆ្នាំ២០១៩** | ៤០.៤០៩ ដុល្លារអាមេរិក | ៣៩.៩៩៩ ដុល្លារអាមេរិក | ១៥.៦០៥ ដុល្លារអាមេរិក | ១៨.៧៩០ ដុល្លារអាមរិក |
| **ថវិកាសម្រាប់អ្នកទទួលផល** | ១,៣៤៧ ដុល្លារអាមេរិក/នាក់ | ១៦ ដុល្លារអាមេរិក/នាក់ | ១,៤១៩ ដុល្លារអាមេរិក/នាក់ | ៤៧០ ដុល្លារអាមេរិក/នាក់ |
| **ខេត្តគ្របដណ្តប់** | កំពង់ចាម ត្បូងឃ្មុំ ក្រចេះ និងព្រៃវែង | កំពង់ចាម ត្បូងឃ្មុំ | កំពង់ចាម ត្បូងឃ្មុំ | ត្បូងឃ្មុំ |
| **ស្រុកគ្របដណ្តប់** | ១១ ស្រុក | ៦ ស្រុក | ៦ ស្រុក | ស្រុកក្រូចឆ្មារ |
| **មធ្យមសិក្សាគោលដៅ** | គ្មាន | ៦ សាលា | គ្មាន | វិ.សម្តេច ហ៊ុន សែន ប៉ើស៕ |
| **សាលាបណ្តុះបណ្តាលវិជ្ជាជីវៈគោលដៅ** | សាកលវិទ្យាល័យ វេស្ទើន ខេត្តកំពង់ចាម | គ្មាន | អង្គការប៉ាស៊ីហ្វិលនុយមេរិកកម្ពុជា, សាកលវិ. Rajamangla, Buriram និងសាកលវិ. Ubon | គ្មាន |
| **កាលបរិច្ឆេទចាប់ផ្តើមគម្រោង** | ០១ តុលា ២០១៦ | ០១ មករា ២០១៩ | ០១ កញ្ញា ២០១៧ | ៣០ វិច្ឆិកា ២០១៧ |
| **កាលបរិច្ឆេទបញ្ចប់គម្រោង** | ៣០ កញ្ញា ២០២០ | ៣១ ធ្នូ ២០១៩ | ៣០ កញ្ញា ២០១៩ | ៣០ កញ្ញា ២០១៩ |















ការអន្តរាគមន៍កម្មវិធីអប់រំបញ្ចូលគ្នាជួយយុវជនកម្ពុជាងាយរងគ្រោះ ដើម្បីទទួលបានឱកាសសិក្សាថ្នាក់ក្រោយមធ្យមសិក្សា។ ឱកាសទាំងនេះធ្វើឱ្យយុវជនមានជំនាញឆ្លើយតបទៅនឹងសតវត្សរ៍ទី២១។ កម្មវិធីអប់រំបញ្ចូលគ្នាផ្តល់ការគាំទ្រដល់ក្មេងប្រុស និងក្មេងស្រីយ៉ាងយកចិត្តទុកដាក់ និងផ្តល់អាទិភាពយ៉ាងខ្លាំងដល់ក្មេងស្រីងាយរងគ្រោះ។ រូបភាពខាងលើ បង្ហាញសកម្មភាពខ្លះៗដែលអនុវត្តនៅក្នុងកម្មវិធីអប់រំបញ្ចូលគ្នា។

**រូបភាពពីខាងឆ្វេង**: **និស្សិតអាហារូបករណ៍ CTSP:** ចូលរួមសិក្ខាសាលានៅសាកលវិទ្យាល័យ សកម្មភាពការងារក្រុម ក្រុមពិភាក្សា និងការស្រាវជ្រាវនៅសាកលវិទ្យាល័យ។ **គម្រោង Access:** សកម្មភាពបណ្តុះបណ្តាល និងទស្សនកិច្ចរបស់ម្ចាស់ជំនួយ។ **គម្រោង STEM4Women:** ម្ចាស់ជំនួយទៅទស្សនកិច្ចនៅសាកលវិទ្យាល័យ ប៊ុរីរ៉ាម និងអ៊ូបុន និងការចុះកិច្ចព្រមព្រៀងរវាងអង្គការ ខេប និងសាកលវិទ្យាល័យ អ៊ូបុន នៅប្រទេសថៃ, កញ្ញា ម៉ម សុភក្ត្រា សិក្សាជំនាញគីមីចំណីអាហារនៅសាកលវិទ្យាល័យ អ៊ូប៊ុន។ **គម្រោង KYLA:** យុវជនចូលរួមវេទិកាអប់រំស្តីពីបរិស្ថាន និងការកែច្នៃសំរាម បទបង្ហាញពីកម្មវិធីត្រីវិស័យ។

# គម្រោង អាហារូបករណ៍និស្សិតកម្រិតឧត្តមសិក្សា (CTSP)

*“ ការអប់រំក្មេងស្រីម្នាក់គឺការអប់រំគ្រួសារទាំងមូល ”*

## បច្ចុប្បន្នភាពគម្រោង

គម្រោងនេះមានគោលបំណងគាំទ្រសិស្សស្រីចំនួន ៣០នាក់ ដែលប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមកពីគ្រួសារដែលមានជីវភាពលំបាកនៅក្នុងខេត្តកំពង់ចាម ដើម្បីបន្តការសិក្សាថ្នាក់បរិញ្ញាបត្រដែលជាជម្រើសពួកគាត់នៅសាកលវិទ្យាល័យ វេស្ទើន ជាស្ថាប័នបណ្តុះបណ្តាលកម្រិតឧត្តមសិក្សានៅក្រុងកំពង់ចាម។ ត្រឹមឆ្នាំ២០១៩នេះ គម្រោងអនុវត្តសកម្មភាពរបស់ខ្លួនបានរយៈពេលបីឆ្នាំហើយ ដូច្នេះ នៅសល់តែមួយឆ្នាំទៀតប៉ុណ្ណោះនិស្សិតអាហារូបករណ៍ទាំងអស់នឹងត្រូវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។ មកដល់ពេលនេះ គម្រោងរំពឹងថាអត្រាបញ្ចប់ការសិក្សាពួកគាត់នឹងទទួលបានជោគជ័យ ១០០ភាគរយ។ និស្សិតចំនួន ៣០នាក់ ដែលកំពុងទទួលអាហារូបករណ៍គឺជាក្រុមនិស្សិតអាហារូបករណ៍ជំនាន់ទី៣មកពីគ្រួសារដែលមានជីវភាពលំបាក។ គម្រោង**CTSP** ជួយដល់ពួកគាត់ដើម្បីសម្រេចបាននូវការសិក្សាប្រកបដោយវិជ្ជាជីវៈខ្ពស់នាំឱ្យពួកគាត់មានការងារល្អប្រសើរ និងប្រែក្លាយជាពលរដ្ឋគំរូសម្រាប់សហគមន៍ទាំងមូល។ គម្រោង **CTSP** កំពុងអនុវត្តដោយអង្គការ ខេប គាំទ្រមូលនិធិ និងជំនួយប្រឹក្សាពីអង្គការមូលនិធិអាស៊ី។ ស្ថាប័នទាំងពីរធ្វើការរួមគ្នាដើម្បីៈ

- គាំទ្រនិស្សិតអាហារូបករណ៍ **CTSP** ដើម្បីរៀនថ្នាក់បរិញ្ញាបត្ររយៈពេលបួនឆ្នាំនៅសាកលវិទ្យាល័យ វេស្ទើន។
- រៀបចំផែនការអភិវឌ្ឍន៍អាជីពប្រកបដោយការឆ្លើយតបរួមជាកញ្ចប់ ដូចជា ថ្នាក់ភាសាអង់គ្លេស កុំព្យូទ័រ បណ្តុះបណ្តាលជំនាញទន់ ទស្សនកិច្ចសិក្សា ក្លឹបសិក្សា ភាពជាអ្នកដឹកនាំ និងការបង្កើតបណ្តាញ។
- ផ្សារភ្ជាប់ជាមួយវិស័យឯកជន និងអង្គការសង្គមស៊ីវិល ដើម្បីបង្កើតឱកាសសម្រាប់និស្សិតអាហារូបករណ៍ទទួលបានការងារហាត់ការ និងកសាងសមត្ថភាពដើម្បីទទួលបានការងារល្អប្រសើរ។

### សកម្មភាពសំខាន់ៗ

- ថ្នាក់ភាសាអង់គ្លេស
- ថ្នាក់កុំព្យូទ័រ
- កម្មវិធី Quick Book
- ប្រជុំប្រចាំខែ
- ជួយគាំទ្រជំនាញទន់ប្រចាំត្រីមាស
- ក្លឹបសិក្សា
- ជួបជុំអតីតនិស្សិតអាហារូបករណ៍
- ជួបជុំអាណាព្យាបាលនិស្សិត
- ប្រជុំប្រចាំឆ្នាំ
- ទស្សនកិច្ចសិក្សា
- បណ្តុះបណ្តាលជំនាញទន់
- ការងារស្ម័គ្រចិត្តក្នុងសហគមន៍
- ជួបជុំជាមួយគ្រឹះស្ថានការងារផ្សេងៗក្នុងឱកាសទទួលបានការងារ ឬហាត់ការងារ
- ទស្សនកិច្ចដោយម្ចាស់ជំនួយ។

## លទ្ធផលកម្មវិធី

- និស្សិត៧នាក់ក្នុងចំណោមនិស្សិតសរុប ៣០នាក់ (២៣%) ទទួលបានបណ្ណសរសើរសម្រាប់និស្សិតជ័យលាភីនៅសាកលវិទ្យាល័យ វេស្ទើន ក្នុងឆ្នាំទី៣ (ខែសីហា ឆ្នាំ២០១៩)។
- និស្សិតទាំងអស់ ៣០នាក់ (១០០%) បានបញ្ចប់ការសិក្សាឆ្នាំទី៣ ដោយជោគ ជ័យនឹងបន្តសិក្សាឆ្នាំទី៤ ចាប់ពីខែកញ្ញា ឆ្នាំ២០១៩ ដល់ខែសីហា ឆ្នាំ ២០២០។
- និស្សិតអាហារូបករណ៍ **CTSP** ទាំងអស់ទទួលបានចំណាត់ថ្នាក់ល្អជាងគេលើគ្រប់មុខវិជ្ជា (ទាំង៥) នៅសាកលវិទ្យាល័យ។
- ចាប់ពីខែសីហា ឆ្នាំ២០១៩ និស្សិត **CTSP** សរុបចំនួន ២១រូប ត្រូវបានជ្រើសរើសធ្វើការនៅ ១០ស្ថាប័ន (អង្គការ ក្រុមហ៊ុនឯកជន)។ ក្នុងនោះ ការងារពេញម៉ោង ចំនួន ១៧នាក់ និងក្រៅម៉ោង ៤នាក់។
- អតីតនិស្សិតអាហារូបករណ៍របស់អង្គការ ខេប ចំនួន ១១០នាក់ បានចូលរួមកម្មវិធីជួបជុំអតីតនិស្សិតអាហារូបករណ៍លើកទី៥។
- គម្រោងបានអនុវត្តផែនការសកម្មភាពអភិវឌ្ឍន៍អាជីពចំនួន ១៣ ក្នុងចំណោមផែនការសរុប ១៥ (៨៧%) ក្នុងឆ្នាំសិក្សា ២០១៨-២០១៩។

កញ្ញា ភួង ស៊ូឡា គឺជានិស្សិតឆ្នាំទី៤ សិក្សាជំនាញធនាគារ និងហិរញ្ញវត្ថុនៅសាកលវិទ្យាល័យ វេស្ទើន។ នាងមានបងប្អូនប្រុស ៤នាក់ ហើយឪពុកម្តាយនាងគឺជាកសិករ។

ស៊ូឡាគឺជាសិស្សពូកែម្នាក់នៅក្នុងគម្រោង CTSP។ នាងទទួលបានចំណាត់ថ្នាក់ល្អ (១-១០) នៅក្នុងថ្នាក់តាំងពីនាងបានចូលរួមក្នុងគម្រោង ហើយនាងចិត្តល្អ និងជួយដល់មិត្តរួមថ្នាក់។

តាមរយៈកម្មវិធីអាហារូបករណ៍ CTSP ស៊ូឡា បានចូលរួមសកម្មភាពជាច្រើន ដូចជាៈ ក្លឹបសិក្សាភាសាអង់គ្លេស និងសិក្សាជំនាញទន់ផ្សេងៗ និងជំនាញកុំព្យូទ័រផងដែរ។ ស៊ូឡាចូលរួមប្រជុំប្រចាំខែយ៉ាងសកម្ម និងការងារស្ម័គ្រចិត្តផ្សេងៗ។ នាងក៏បានធ្វើជាប្រធានក្លឹបអំណានជាភាសាអង់គ្លេស និងបានចូលរួមស្ម័គ្រចិត្តសម្របសម្រួលសកម្មភាពការងារសង្គមនៅក្នុងគម្រោងយុវជនវ័យក្មេងនៅកម្ពុជា(KYLA) ផងដែរ។

នៅខែកញ្ញា ឆ្នាំ២០១៩នេះ ស៊ូឡាត្រូវបានជ្រើសរើសជាបុគ្គលិកប្រចាំនៅសាខាធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA) ក្រុងកំពង់ចាម ខេត្តកំពង់ចាម៕






កញ្ញា ថន ណារិន គឺជានិស្សិតសិក្សាជំនាញគ្រប់គ្រង និងបញ្ចប់ថ្នាក់បរិញ្ញាបត្រនៅឆ្នាំ ២០២០ ខាងមុខនេះ។ ណារិនតែងតែទទួលបានចំណាត់ថ្នាក់លេខ១ តាំងពីចូលរួមក្នុងគម្រោង។ នាងមានភាពក្លាហាន ជួយអ្នកដទៃ ចូលចិត្តអានសៀវភៅ និងជួយបង្រៀនមិត្តភក្តិធ្វើលំហាត់លើមុខវិជ្ជាហិរញ្ញវត្ថុ និងចូលចិត្តការងារសង្គម។ ណារិនទទួលបានជ័យលាភីស្តីពីសំណេរជាភាសាអង់គ្លេសទៅលើប្រធានបទ (សមាគមអាស៊ាន) របស់មូលនិធិ One Asia Foundation, ទទួលបានកញ្ចប់ថវិកាពីអង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP) ដើម្បីរៀបចំសិក្ខាសាលាៈ ស្តីពីសុខភាព និង អប់រំនៅតំបន់ដាច់ស្រយាល។ ណារិនទទួលបណ្ណសរសើរស្តីពីៈ ការប្រកួតជជែកដេញដោលនៅសាកលវិទ្យាល័យ វេស្ទើន ផ្អែកលើភាពប៉ិនប្រសប់ និងការបញ្ចេញគំនិតរបស់នាង។ នៅខែកញ្ញានេះ ណារិនត្រូវបានជ្រើសរើសធ្វើជាមន្ត្រីគម្រោងនៅអង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីការអភិវឌ្ឍសង្គម (BSDA) ជាអង្គការធំមួយនៅខេត្តកំពង់ចាម។ នៅចុងបញ្ចប់ការសម្ភាស ណារិនបាននិយាយថា *“ខ្ញុំពិតជាសប្បាយចិត្តជាខ្លាំងដែលបានធ្វើការងារនៅអង្គការក្រៅរដ្ឋាភិបាលក្នុងការជួយក្មេងៗដែលមកពីគ្រួសារជីវភាពលំបាកដើម្បីឱ្យពួកគេមានជម្រើសនៅក្នុងជីវិត។ ខ្ញុំនឹងបន្តព្យាយាមរៀនសូត្រពីជីវិតដើម្បីធ្វើការអភិវឌ្ឍខ្លួនឯងជាប្រចាំ។ នៅពេលអនាគតដ៏ខ្លីខាងមុខនេះ ខ្ញុំសង្ឃឹមថានឹងមានឱកាសក្លាយជាប្រធានគម្រោង*”៕

# គម្រោងសកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា (KYLA)

*“ពង្រឹងអំណាចដល់យុវជនដើម្បីក្លាយជាអ្នកដឹកនាំ”*

## បច្ចុប្បន្នភាពគម្រោង

គម្រោងសកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា( KYLA ) គឺជាគម្រោងថ្មីមួយរបស់អង្គការ ខេប។ គម្រោងនេះទទួលបានមូលនិធិពីអង្គការអូកទ្រី និងរដ្ឋាភិបាលអូស្រ្តាលី ប្រតិបត្តិដោយអង្គការ ខេប ក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ។ គំនិតសំខាន់គម្រោងនេះគឺកៀរគរអតីតនិស្សិតអាហារូបករណ៍ខេបជាច្រើនរយនាក់ចូលរួមរៀបចំសកម្មភាពបណ្តុះបណ្តាល និងវេទិកាតស៊ូមតិដល់យុវជននៅក្នុងសាលា។ ទាំងនេះរួមមាន៖ ការផ្តល់ពេលវេលា និងថវិកាដើម្បីគាំទ្រអាហារូបករណ៍ រៀបចំសិក្ខាសាលា និងគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីចែករំលែកព័ត៌មាន។ ក្រុមអ្នកគ្រប់គ្រងដែលជាអតីតនិស្សិតអាហារូបករណ៍របស់អង្គការ ខេប ដែលបង្កើតឡើងដោយមានរចនាសម្ព័ន្ធ និងតួនាទីច្បាស់លាស់ ជួយសម្របសម្រួលសកម្មភាពជាច្រើន។

## សកម្មភាពសំខាន់ៗ

- បណ្តុះបណ្តាលជំនាញទន់ ដូចជា៖ (ភាពជាអ្នកដឹកនាំ ការនិយាយជាសាធារណៈ ទំនាក់ទំនង ការងារក្រុម ការដោះស្រាយបញ្ហា វិភាគបញ្ហា និងការបង្កើតបណ្តាញ )។
- បណ្តុះបណ្តាលស្តីពីការពង្រឹងសិទ្ធិអំណាចស្ត្រី ( សិទ្ធិរបស់ប្រជាពលរដ្ឋ សិទ្ធិសេដ្ឋកិច្ច និងវប្បធម៌ )។
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីផ្តល់ព័ត៌មានដល់យុវជននូវជម្រើសអាជីព (តាមរយៈហ្វេសប៊ុក សារអេឡិចត្រូនិច ឡាញ និងវីដេអូ...)។
- បណ្តុះបណ្តាលស្តីពីការបង្កើតអត្ថបទរឿង និងវីដេអូខ្លីៗ។
- ប្រឹក្សាយោបល់អាជីពតាមអេឡិចត្រូនិច និងរៀបចំផែនការអាជីពនៅតាមសាលា។
- រៀបចំកម្មវិធីជួបជុំអតីតសិស្សអាហារូបករណ៍អង្គការ ខេប។
- ចូលរួមប្រជុំដែលរៀបចំដោយក្រុមការងារបច្ចេកទេសលើវិស័យអប់រំ ( **ESWGs** )។

## គោលដៅ

បង្កើនឱកាសដល់យុវជនដើម្បីបំពេញនូវសក្តានុពលភាពរបស់ពួកគាត់ តាមរយៈការផ្តល់សិទ្ធិអំណាចក្នុងការដឹកនាំដោយក្រុមយុវជន និងកៀរគរធនធានដែលជាប្រយោជន៍ដល់យុវជន នៅក្នុងសង្គម រួមមាន៖ ស្ថាប័នអប់រំ រដ្ឋាភិបាល និងសង្គមទូទៅ។

## រូបភាពសកម្មភាព

វេទិកាអប់រំស្តីពីបរិស្ថានៈ នៅក្នុងអំឡុងខែកក្កដា គម្រោង **KYLA** បានសម្របសម្រួលវេទិកាអប់រំស្តីពី**បរិស្ថាននៅតាមសាលាគោលដៅទាំង ៦**។ របៀបវារៈកម្មវិធីទាំងអស់ត្រូវបានបង្កើតឡើង និងកិច្ចសហការរវាងនិស្សិតស្ម័គ្រចិត្ត និងសិស្សនៅវិទ្យាល័យ។ ប្រធានមន្ទីរខេត្ត មេឃុំ លោកគ្រូ/អ្នកគ្រូ តំណាងមន្ត្រីបរិស្ថាន អាណាព្យាបាល សិស្សានុសិស្ស និងបុគ្គលិកអង្គការ បានចូលរួមក្នុងកម្មវិធីនេះសរុបប្រហែលជាង ២០០០នាក់។ វេទិកានេះបានបង្ហាញពីលទ្ធភាពរបស់គម្រោង ដើម្បីទំនាក់ទំនង និងជាការផ្តួចផ្តើមគំនិតយុវជនក្នុងការរៀបចំកម្មវិធីជាផ្លូវការ ដែលមានការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗនៅក្នុងសហគមន៍។ សិស្សស្ម័គ្រចិត្តក្នុងគម្រោង **KYLA** មានឱកាសក្នុងការអនុវត្តការនិយាយជាសាធារណៈ ជំនាញក្នុងការធ្វើបទបង្ហាញ និងការរៀបចំផែនការ។ ប្រធានបទរួមមាន៖ ផលប៉ះពាល់ការបំពុលខ្យល់ ការកាប់បំផ្លាញព្រៃឈើ និងបំពុលកាកសំណល់រឹងដែលប៉ះពាល់ដល់ជីវិតរស់នៅរបស់ប្រជាពលរដ្ឋ។





*សិស្សស្ម័គ្រចិត្តចំនួន ១៥០នាក់ នៅតាមសាលាគោលដៅទាំង ៦ ចូលរួមធ្វើបទបង្ហាញក្នុងវេទិកាអប់រំស្តីពីបរិស្ថាន។*

**ទស្សនកិច្ចនៅទីក្រុងភ្នំពេញ**: *នៅខែសីហា ឆ្នាំ២០១៩ គម្រោង KYLA បានដឹកនាំសិស្សចំនួន ១៣នាក់ ទៅទស្សនកិច្ចសិក្សានៅទីក្រុងភ្នំពេញ។ ពួកគាត់ទៅជួបជាមួយស្ថាប័នផ្សេងៗ ដូចជា៖ ក្រុមហ៊ុន Arrow Dot អង្គការ UNV កម្ពុជា និងអង្គការ InSTEDD iLab ។ ទស្សនកិច្ចសិក្សានេះបានជួយសិស្សស្វែងយល់កាន់តែប្រសើរនៃដំណើរការតស៊ូមតិ ជំនាញព័ត៌មានវិទ្យា និងការអភិវឌ្ឍសង្គម។*



*នៅខែវិច្ឆិកា ឆ្នាំ២០១៩ គម្រោង KYLA បានរៀបចំវេទិកាអប់រំស្តីពីប្រឹក្សាអាជីពតាមរយៈកម្មវិធីត្រីវិស័យ។ សិស្សស្ម័គ្រចិត្តមកពីសាលាគោលដៅទាំង៦ធ្វើបទបង្ហាញពីរបៀបប្រើប្រាស់កម្មវិធីត្រីវិស័យ និងសម្រាប់សិស្សថ្នាក់ទី ៩-១២ ដើម្បីទទួលបានជម្រើសអាជីពសម្រាប់ថ្ងៃអនាគត។*



*ក្រុមអតីតនិស្សិតអាហារូបករណ៍របស់គម្រោង KYLA បានអញ្ជើញបុគ្គលិកជំនាញទំនាក់ទំនងមកពីអង្គការ InSTEDD iLab ដើម្បីបណ្តុះបណ្តាលសិស្សវិទ្យាល័យ។ ពួកគាត់បានរៀនពីរបៀបសរសេររឿងខ្លីទាក់ទងនឹងការបង្កើតវីដេអូ ដោយប្រើប្រាស់កម្មវិធីក្នុងទូរសព្ទដៃ និងកុំព្យូទ័រ ។*

# គម្រោង STEM4WOMEN ( ស្ទែម/STEM )

*“ ការអប់រំផ្លួយចម្លងជីវិតស្ត្រីកម្ពុជា ”*

## បច្ចុប្បន្នភាពគម្រោង

អង្គការ ខេប ជាដៃគូសហការជាមួយ *Classroom of Hope (CoH)* ដើម្បីពង្រឹងសិទ្ធិអំណាច និងបង្កើនការចូលរួមរបស់យុវតីលើមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វករ និងគណិតវិទ្យា *(STEM)*។ ឆ្នាំនេះ គម្រោង *STEM4Women* ទទួលបានជំនួយពី *Navitas* និង *Classroom of Hope* និងអនុវត្តសកម្មភាពដោយអង្គការខេប។ គម្រោង បានផ្តល់ជំនួយដល់ក្មេងស្រីចំនួន ១១នាក់ ដើម្បីបន្តការសិក្សារយៈពេល ២ឆ្នាំនៅកម្រិតឧត្តមសិក្សាលើមុខជំនាញស្ទែម។ អង្គការ ខេប បានចរចាដោយចុះអនុស្សរណៈយោគយល់ជាមួយស្ថាប័នមួយចំនួន ដើម្បីទទួលសិស្សកម្ពុជា។ ស្ថាប័នទាំងនេះ រួមមាន៖ សាកលវិទ្យាល័យ រ៉ាចាម៉ាំងខ្លា (ថៃ), សាកលវិទ្យាល័យ អ៊ូប៊ុន (ថៃ) សាកលវិទ្យាល័យ ប៊ូរីរ៉ាម (ថៃ), និងអង្គការប៉ាសឺរ៉ែលនុយមឺរិក (កម្ពុជា)។ គម្រោងអាចចរចារជាមួយស្ថាប័ន ដោយលក្ខខណ្ឌល្អប្រសើរជាមួយនឹងថ្លៃការសិក្សា និងស្នាក់នៅដោយឥតគិតថ្លៃ។ អ្នកទទួលផលពីគម្រោងគឺមកពីគ្រួសារដែលមានជីវភាពខ្វះខាត ងាយរងគ្រោះ ពិសេសក្មេងស្រីមានឱកាសតិចតួចដើម្បីបន្តការសិក្សាកម្រិតខ្ពស់។

### គោលបំណង

ផ្តល់សិទ្ធិអំណាចដល់យុវតីនៅកម្ពុជាដែលងាយរងគ្រោះ ទទួលបានការសិក្សាមុខជំនាញស្ទែមដែលបច្ចុប្បន្នជំនាញនេះបុរសជាអ្នកសិក្សា។

### មុខវិជ្ជា

- គីមីចំណីអាហារ
- សិល្បៈច្នៃប្រឌិត
- អាហាររូបត្ថម្ភ
- វិទ្យាសាស្ត្រដាំដុះ
- គណនេយ្យ
- កុំព្យូទ័រ
- កម្មវិធីផេបសាយ
- គ្រប់គ្រងបណ្តាញ



កញ្ញា មាស ឆេងស៊ាង មានអាយុ ២០ឆ្នាំ និងទទួលបានអាហារូបករណ៍ពីគម្រោង STEM 4Women នៅក្នុងឆ្នាំ២០១៨។ នាងកំពុងរៀនជំនាញគីមីចំណីអាហារនៅមហាវិទ្យាល័យ BCAT នៅក្នុងខេត្តប៊ូរីរ៉ាម ក្នុងប្រទេសថៃ។ នាងជាសិស្សពូកែ និងឧស្សាហ៍ម្នាក់ ហើយថ្មីៗនេះ នាងទទួលបានពិន្ទុ GPA៣.៥៨ នៅចុងឆ្នាំទី១។ នាងពូកែនិយាយភាសាអង់គ្លេស និងមុខវិជ្ជាជាច្រើនក្នុងថ្នាក់រៀន។ ឆេង ស៊ាង រៀនក្នុងថ្នាក់ប្រើភាសាថៃ និងនាងអាចនិយាយបានច្រើនភាសា។ នៅខែមេសា ឆ្នាំ២០១៩ នាងបានហាត់ការងារជាមន្ត្រីត្រួតពិនិត្យគុណភាពអាហារនៅក្រុមហ៊ុនមួយនៅប្រទេសថៃ និងមានផែនការត្រឡប់មកកម្ពុជាវិញបន្ទាប់ពីរៀនចប់ថ្នាក់បរិញ្ញាបត្ររងនៅឆ្នាំ២០២០៕

**មាស ឆេងស៊ាង**
*ជំនាញគីមីចំណីអាហារ*



*ការចុះអនុស្សរណៈយោគយល់គ្នារវាងអង្គការ ខេប និងសាកលវិទ្យាល័យ អ៊ុប៊ុន ប្រទេសថៃ*



*កញ្ញា ម៉ម សុភក្ត្រា ជានិស្សិតផ្នែកអាហារូបត្ថម្ភនៅសាកលវិទ្យាល័យ អ៊ុប៊ុន (ប្រទេសថៃ)។*




*ម្ចាស់ជំនួយ និងប្រធានកម្មវិធីអប់រំបញ្ចូលគ្នា អង្គការ ខេប បានទស្សនកិច្ចនិស្សិតនៅក្នុងគម្រោង STEM4Women រៀននៅសាលា អ៊ុប៊ុនប្រទេសថៃ។*



**កញ្ញា ឌុច សាម៉ៃ**
*អ្នកបង្កើតកម្មវិធីសុសវែរ*

កញ្ញា ឌុច សាម៉ៃ បានបញ្ចប់ថ្នាក់បរិញ្ញាបត្ររងលើជំនាញ វេបឌីហ្សាញ ពីអង្គការប៉ាសឺរ៉ែលនុយមឺរិកកម្ពុជា នៅខែសីហា ឆ្នាំ២០១៩។ បច្ចុប្បន្ន នាងកំពុងបម្រើការងារនៅក្រុមហ៊ុន Rotati Consulting មានតួនាទីជាអ្នកបង្កើតកម្មវិធីសុសវែរ និងបានចូលរួមបង្កើតប្រព័ន្ធកត់ត្រាទិន្នន័យក្មេងនៅសាលាដើម្បីជួយសម្រួលដល់អង្គការក្រៅរដ្ឋាភិបាលក្នុងការផ្តល់សេវាផ្សេងៗ។ នាងចូលចិត្តកន្លែងធ្វើការនាងណាស់ ហើយនាងជួបមនុស្សពូកែជាច្រើនរៀងរាល់ថ្ងៃ។ សាម៉ៃគឺជាបុគ្គលតែម្នាក់គត់ដែលបានបញ្ចប់ការសិក្សាកម្រិតឧត្តមសិក្សានៅក្នុងគ្រួសារ។ បងប្អូនរបស់នាងបានបោះបង់ការសិក្សាតាំងពីពួកគេរៀននៅកម្រិតបឋមសិក្សា។ ម្តាយរបស់សាម៉ៃបានស្លាប់តាំងពីនាងរៀននៅអនុវិទ្យាល័យ ប៉ុន្តែនាងជឿជាក់ថា ម្តាយរបស់នាងពិតជាមានមោទនភាពដែលនាងបានរៀនដល់ថ្នាក់បរិញ្ញាបត្រ ហើយបានធ្វើការនៅក្រុមហ៊ុនដ៏ធំនៅទីក្រុងភ្នំពេញ៕



*Ms. Thai Youlen attended the parent day.*

# កម្មវិធីអាហារូបករណ៍ភាសាអង់គ្លេសខ្នាតតូច (Access)

*“ ផ្តល់ជំនាញភាសាអង់គ្លេស និងចំណេះដឹងពីវប្បធម៌សហរដ្ឋអាមេរិកតាមរយៈបរិស្ថានសិក្សារីករាយ ”*

## ប្រវត្តិគម្រោង

Access គឺជាកម្មវិធីអាហារូបករណ៍សាកល ដែលផ្តល់នូវជំនាញភាសាអង់គ្លេសថ្នាក់មូលដ្ឋានលើសិស្សពូកែ ជួបការលំបាកខាងសេដ្ឋកិច្ច ដែលមានអាយុចាប់ពី ១៣ ដល់ ២០ឆ្នាំ តាមរយៈសកម្មភាពលើកកម្ពស់ផ្សេងៗ។ តាំងពីឆ្នាំ២០០៤ សិស្សជាង ១១៥.០០០នាក់មកពី ៨៥ប្រទេស បានចូលរួមក្នុងកម្មវិធីអាហារូបករណ៍ភាសាអង់គ្លេសខ្នាតតូច។ ថ្មីៗនេះអង្គការ ខេប ក៏ទទួលបានថវិកាពីស្ថានទូតអាមេរិកដើម្បីដំណើរការកម្មវិធី អាហារូបករណ៍ ភាសាអង់គ្លេសខ្នាតតូច Access ផងដែរ។

អង្គការ ខេប បានដំណើរការកម្មវិធី Access រយៈពេលពីរឆ្នាំ (២០១៧-១៩) ចំនួនសិស្ស ៤០នាក់នៅវិទ្យាល័យសម្តេច ហ៊ុន សែន បើុស ॥ នៅក្នុងខេត្តត្បូងឃ្មុំ ទទួលថវិកាពីក្រសួងការបរទេសអាមេរិក។ សិស្សបានរៀនភាសាអង់គ្លេសដ៏ពូកែ ដែលជួយពួកគេទៅរកការងារល្អប្រសើរ និងឱកាសសិក្សាកាន់តែច្រើន។ បើទោះបីជាគម្រោងបានបញ្ចប់នៅក្នុងខែកញ្ញា ឆ្នាំ២០១៩នេះក៏ដោយ អង្គការ ខេប កំពុងចរចារក្នុងការបន្តគម្រោងនេះមួយឆ្នាំទៀតពីស្ថានទូតអាមេរិក ដែលសង្ឃឹមថាអាចនឹងចាប់ផ្តើមនៅឆ្នាំ២០២០។

## ផលជះរបស់កម្មវិធី

- សិស្ស Access ចំនួន ១០០% បានចូលរៀន និងបញ្ចប់ការសិក្សាដោយជោគជ័យ។
- សិស្ស Access ទាំង ៤០នាក់ បានចូលរួមទស្សនកិច្ចសិក្សានៅស្ថានទូតអាមេរិកភ្នំពេញ ចូលរួមសាលា និងសិស្សដទៃទៀតដែលបានចូលរួមក្នុងកម្មវិធី Access។
- សិស្ស Access ទាំងអស់បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការកំណត់គោលដៅ។
- សិស្ស Access ១៥ នាក់ បានចូលរួមកម្មវិធីចែករំលែកឱកាសអាហារូបករណ៍ទៅអាមេរិករៀបចំដោយសមាគម FUSAAC។
- សិស្ស Access ៤០ នាក់បានចូលរួមកម្មវិធីបោះជំរុំរៀបចំដោយស្ថានទូតអាមេរិក។
- សិស្សទាំងអស់បានចូលរួមគម្រោងអភិវឌ្ឍន៍សហគមន៍ ដែលរួមមានការលើកឡើងពីតម្រូវការសម្រាប់ការកែច្នៃសំរាមនៅបឋមសិក្សា
- សិស្សបានសិក្សាជំនាញបន្ទាប់បន្សំដែលចាំបាច់ ដូចជា ICT ដែលជួយពួកគេបង្កើនការរៀនភាសាអង់គ្លេសឱ្យកាន់តែខ្លាំង។

## គោលបំណង

លើកកម្ពស់ចំណេះដឹងសិស្សអំពីវប្បធម៌សហរដ្ឋអាមេរិក ជំនាញភាសាអង់គ្លេស និងជំនាញគិតពិចារណាស៊ីជម្រៅតាមរយៈបច្ចេកទេសបង្រៀនប្រកបដោយភាពច្នៃប្រឌិត។

## សកម្មភាពសំខាន់ៗ

- បង្រៀនភាសាអង់គ្លេសចំនួន ៨ ម៉ោងក្នុងមួយសប្តាហ៍
- បង្រៀន ICT ចំនួន ២ ម៉ោងក្នុងមួយសប្តាហ៍ជាភាសាអង់គ្លេស
- បង្រៀនភាសាអង់គ្លេសជាង ៦០០ ម៉ោងសម្រាប់សិស្សម្នាក់
- ផ្តល់ការគាំទ្រសម្រាប់ការសិក្សារួមមាន៖ កង់ កាតាប ថ្លៃអាហារ និងសៀវភៅអង់គ្លេស
- គម្រោងសេវាកម្មសង្គម
- សកម្មភាពអភិវឌ្ឍន៍ខ្លួនឯង
- កម្មវិធីបំណិនជីវិតបន្លែលើទឹក (ជលវប្បកម្ម)។
- ចំណេះដឹងពីវប្បធម៌អាមេរិក
- បោះជំរុំ ជំនួបជាមួយសាលា និងទស្សនកិច្ចនៅស្ថានទូតអាមេរិក
- ប្រជុំឪពុកម្តាយ និងសហគមន៍
- ពិធីប្រគល់វិញ្ញាបនបត្រដោយតំណាងស្ថានទូតអាមេរិកប្រចាំនៅកម្ពុជា។

**ទស្សនកិច្ចសិក្សាទៅស្ថានទូតអាមេរិកនៅទីក្រុងភ្នំពេញ៖** មនុស្សមួយក្រុមមានគ្នាសរុបចំនួន ៤៤នាក់ ដែលរួមមាន សិស្ស Access គ្រូ និងបុគ្គលិកអង្គការ ខេប ត្រូវបានអញ្ជើញទៅទស្សនកិច្ចនៅស្ថានទូតអាមេរិក ដែលជាផ្នែកមួយនៃទស្សនកិច្ចសិក្សា ដើម្បីជួយសិស្សឱ្យយល់ដឹងអំពីសារៈសំខាន់ភាសាអង់គ្លេស។ សិស្សបានចូលរួមប្រជុំស្តីពីការដាក់អាហារូបករណ៍ចូលរៀននៅកម្រិតមហាវិទ្យាល័យគ្រឹះស្ថានអប់រំនៅសហរដ្ឋអាមេរិក ដែលចែករំលែកដោយអ្នកណែនាំនៅស្ថានទូតអាមេរិក។ នេះគឺជាបទពិសោធដ៏អស្ចារ្យ និងលើកទឹកចិត្តជាខ្លាំងសម្រាប់សិស្សមកពីតំបន់ដាច់ស្រយាល។ សិស្សបានទៅមើលបន្ទប់ *Jacqueline Kennedy* និងបានរៀនពីតួនាទីរបស់នាងក្នុងការកែលម្អទំនាក់ទំនងរវាងអាមេរិក និងកម្ពុជាឡើងវិញនៅក្នុងឆ្នាំ១៩៦៧។ ស្ថានទូតក៏បានរៀបចំសាលាមួយចំនួនដើម្បីបង្កើតទំនាក់ទំនង រួមមាន៖ សាលា *Sustainable School International (SSI)* និងសាលា *Liger Institute* ដែលសិស្សទាំងអស់អាចជជែក និងចែករំលែកគំនិតគ្នាទៅវិញទៅមក។ ទស្សនកិច្ចរយៈពេល៣ថ្ងៃ និងការជួយគាំទ្រដោយអង្គការ ខេប ធ្វើឱ្យសិស្សទទួលបានបទពិសោធន៍ផ្លាស់ប្តូរជីវិត និងមានឥទ្ធិពលដល់ផែនការអនាគតពួកគេ។



*សិស្ស Access បានចូលរួមរៀនភាសាអង់គ្លេសពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ។*



*សិស្សចំនួន ៤០នាក់ បានបញ្ចប់ការសិក្សាភាសាអង់គ្លេសដោយជោគជ័យក្នុងគម្រោងអាហារូបករណ៍ភាសាអង់គ្លេសខ្នាតតូច។ នេះជាកម្មវិធីអបអរសាទរ និងទទួលវិញ្ញាបនបត្រពីតំណាងស្ថានទូតអាមេរិកប្រចាំប្រទេសកម្ពុជា។*

***ម្ចាស់ជំនួយមកពីស្ថានទូតអាមេរិក៖*** *តំណាងមកពីស្ថានទូតអាមេរិកចំនួន ៦-៧នាក់ បានអញ្ជើញមកទស្សនកិច្ចសិស្ស Access នៅវិទ្យាល័យសម្តេច ហ៊ុន សែន បើុស ॥ ដើម្បីយល់ដឹងពីភាពជោគជ័យរបស់គម្រោង។ នេះគឺជាការសន្ទនារបស់តំណាងស្ថានទូតអាមេរិក និងសិស្ស Access ៤នាក់ អំពីទំនាក់ទំនងរវាងវប្បធម៌កម្ពុជា និងអាមេរិក ហើយរបៀបដែលគម្រោងបានជួយពួកគាត់ដើម្បីកែលម្អឱ្យក្លាយជាជនគំរូ។*



# គម្រោង កុមារកម្ពុជារីករាយ (HCC)

“រៀនដើម្បីចេះអាន អានដើម្បីមានចំណេះដឹង”

## ប្រវត្តិកម្មវិធី

| | |
|---|---|
| **ម្ចាស់អំណោយ** | គីនឆាន ស្ទីហ្វទុង |
| **ចំនួនអ្នកទទួលផលផ្ទាល់** | សិស្សសរុប ៨.៤៩៨នាក់<br>សិស្សជនជាតិភាគតិច ២.១៨៨នាក់ |
| **ថវិកាទទួលឆ្នាំ២០១៩** | ៥៨៧,៤៧៨ ដុល្លាអាមេរិក |
| **តម្លៃជាមធ្យមសិស្សម្នាក់** | ៦៩ ដុល្លាអាមេរិក |
| **ចំនួនខេត្តគ្រប់ដណ្តប់** | ៥ខេត្ត (សៀមរាប ត្បូងឃ្មុំ កំពង់ចាម ក្រចេះ និងរតនគីរី) |
| **ចំនួនស្រុកគ្រប់ដណ្តប់** | ៨ ស្រុក |
| **សាលាគោលដៅបឋម** | ២៥សាលា |
| **កាលបរិច្ឆេទចាប់ផ្តើមគម្រោង** | ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៨ |
| **កាលបរិច្ឆេទបញ្ចប់គម្រោង** | មិនកំណត់ |

## គោលបំណង

- **គោលបំណងទី១៖** ពង្រឹងលទ្ធភាពទទួលបានសេវាអប់រំឱ្យមានភាពប្រសើរឡើងនៅតំបន់គោលដៅ (ពិសេសសម្រាប់កុមារី និងកុមារងាយរងគ្រោះ)។
- **គោលបំណងទី២៖** ពង្រឹងប្រសិទ្ធភាពបង្រៀន និងរៀន (គុណភាពអប់រំ) ឱ្យមានភាពប្រសើរឡើងតាមរយៈការអភិវឌ្ឍ និងការអនុវត្តកម្មវិធីសាលាកុមារមេត្រីក្នុង និងក្រៅថ្នាក់រៀនតាមរបៀបដែលពាក់ព័ន្ធនឹងតម្រូវការរបស់កុមារ ជាពិសេសកុមារងាយរងគ្រោះ និងកុមារី។
- **គោលបំណងទី៣៖** ពង្រឹងសកម្មភាពអំណានថ្នាក់ដំបូងរបស់កុមារឱ្យបានប្រសើរឡើងពិសេសសម្រាប់កុមាររៀនថ្នាក់ទី១, ២ និងទី៣។
- **គោលបំណងទី៤៖** កែលម្អសមត្ថភាពគ្រប់គ្រងដៃគូនៅមូលដ្ឋាន ដើម្បីបង្កើនលទ្ធភាពទទួលបានសេវាអប់រំ និងគុណភាពបង្រៀននិងរៀន ក៏ដូចជាការផ្សព្វផ្សាយនៅតាមសហគមន៍។

## បច្ចុប្បន្នភាពគម្រោង

គម្រោងកុមារកម្ពុជារីករាយបានផ្លាស់ប្តូរឈ្មោះពីគម្រោងសហសាលាកម្ពុជា(USC)។ គម្រោងនេះបានចាប់ផ្តើមនៅខែសីហា ឆ្នាំ២០១៨ ដោយមានការផ្តល់មូលនិធិពីមូលនិធិគីនឆានស្ទីហ្វទុងដែលផ្តោតលើការគាំទ្រដល់កុមារនៅតាមសហគមន៍ជនបទ និងដាច់ស្រយាលបំផុតនៅក្នុងខេត្តចំនួន ៥ ដែលមានបញ្ហាប្រឈមជាច្រើនទាក់ទងនឹងសមត្ថភាពធនធានមនុស្សនៅតាមសាលាគោលដៅ ការត្រួតពិនិត្យខាងសម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធដែលមានភាពទ្រុឌទ្រោម។ កង្វះគ្រូគឺជាបញ្ហាចម្បងមួយដែលគម្រោងកំពុងព្យាយាមដោះស្រាយ។ ការធ្វើតេស្តដំបូងលើការអានបានបង្ហាញថាកម្រិតអាននៅមានកម្រិតទាប ដោយកុមារ ៧៥% នៅក្នុងថ្នាក់ទី១ ដល់ទី ៣ មិនអាចអានបានសូម្បីតែមួយពាក្យ។ ទោះបីជាពិន្ទុសូន្យទាំងនេះបានធ្លាក់ចុះដល់ ៤២% នៅការធ្វើតេស្តពាក់កណ្តាលឆ្នាំ គម្រោងនេះនៅតែមិនអាចទទួលយកបានទេ ហើយត្រូវការវិនិយោគជាយុទ្ធសាស្ត្រជាច្រើនឆ្នាំបន្តបន្ទាប់ទៀត។

## សកម្មភាពសំខាន់ៗ

- គាំទ្រសកម្មភាពសាលាមត្តេយ្យ១កន្លែង (ឃុំហាន់ជ័យ)
- ផ្តល់ការគាំទ្រយ៉ាងពេញលេញលើការលើកកម្ពស់កម្មវិធីអំណានដែលប្រើវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (TRAC)។ នេះពាក់ព័ន្ធនឹងការវាយតម្លៃបន្តបន្ទាប់យ៉ាងហ្មត់ចត់ផ្អែកលើសៀវភៅស្តង់ដាអំណានក្រសួង និងការផ្គូរផ្គងអ្នកមានបញ្ហាអានប្រើប្រាស់ប្រព័ន្ធជាមួយនឹងការអន្តរាគមន៍សំខាន់ៗ ដូចជា ការបង្រៀនតាមបែបមិត្តជួយមិត្ត ការខ្ចីសៀវភៅ ជាពិសេសនៅបណ្ណាល័យ និងការចុះដល់ផ្ទះឪពុកម្តាយ ដើម្បីចូលរួមជាមួយឪពុកម្តាយក្នុងការអានរបស់កូនពួកគាត់។
- ធ្វើឱ្យប្រសើរនូវសកម្មភាពបណ្ណាល័យដើម្បីធានាបរិស្ថានអានមានភាពទាក់ទាញ និងមានភាពងាយស្រួលក្នុងការប្រើសៀវភៅ និងសម្ភារសិក្សា និងការគ្រប់គ្រងល្អប្រសើរ។
- វិនិយោគធំៗធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ ផ្តោតលើការជួសជុលអគារថ្មជាមួយការរៀបចំការ៉ូ លាបថ្នាំ ពិដានដំបូល ការជួសជុលគ្រឿងសង្ហារឹម និងការជួសជុលបង្គន់។
- ការបង្កើតក្រុមប្រឹក្សាកុមារដើម្បីលើកកម្ពស់ភាពជាម្ចាស់កុមារលើសាលារៀន និងធ្វើឱ្យប្រសើរនូវអភិបាលកិច្ច។
- ការធ្វើឱ្យប្រសើរបណ្ណាល័យ និងភាពងាយស្រួលប្រើប្រាស់ឧបករណ៍អានដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងកម្មវិធីសិក្សា។
- ការគ្រប់គ្រងរដ្ឋបាលវាយតម្លៃអំណានកម្រិតដំបូង (EGRA) ចាប់ផ្តើមនិងពាក់កណ្តាលគម្រោងដើម្បីតាមដានផលជះលើលទ្ធផលសិក្សាសិស្ស។
- ការកែលម្អថ្នាក់រៀនរួមទាំងការផ្តល់សម្ភារៈជំនួយសម្រាប់ការបង្រៀន និងរៀន ក៏ដូចជាការបណ្តុះបណ្តាលអំពីរបៀបប្រើសម្ភារៈផងដែរ។
- គាំទ្រអាហារូបករណ៍ដល់កុមារងាយរងគ្រោះបំផុត។
